ក្រសួងព័ត៌មាន

# ផែនការសកម្មភាព
# ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
# សម្រាប់ក្រសួងព័ត៌មាន
# ២០១៥-២០១៨

២០១៥

ក្រុមការងារបច្ចេកទេសនៃការប្រែប្រួលអាកាសធាតុរបស់ក្រសួងព័ត៌មាន

ក្រសួងព័ត៌មាន

# ផែនការសកម្មភាព
# ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
# សម្រាប់ក្រសួងព័ត៌មាន
# ២០១៥-២០១៨

២០១៥

ក្រុមការងារបច្ចេកទេសនៃការប្រែប្រួលអាកាសធាតុរបស់ក្រសួងព័ត៌មាន

## អារម្ភកថា

ការទទួលបានព័ត៌មានដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងលទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជា ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ២០១៤-២០១៨ បានកំណត់សមិទ្ធផលគោលដៅ សម្រាប់វិស័យព័ត៌មាន ដោយផ្តោតការយកចិត្តទុកដាក់លើប្រព័ន្ធព័ត៌មាន ប្រកបដោយគុណភាព (ទូរទស្សន៍ វិទ្យុផ្សាយសម្លេង ការបោះពុម្ពផ្សាយ និងប្រព័ន្ធអ៊ីនធើណិត) ពង្រីកតំបន់គ្របដណ្តប់ដល់ទៅ៨៥%នៃប្រជាជន ៦៤%នៃគ្រួសារមានទូរទស្សន៍ ៤១%មានវិទ្យុ និង២០%ប្រើប្រាស់អ៊ីនធើណិត។ ការទទួលបានព័ត៌មាននៅថ្នាក់ក្រោមជាតិក៏មានការរីកដុះដាលខ្លាំង។ស្ថានីយផ្សាយបន្តមាននៅ១៧ខេត្តដើម្បីផ្សាយបន្តព្រឹត្តិការណ៍សំខាន់ៗនិងផ្សាយកម្មវិធីក្នុងតំបន់របស់គេដើម្បីជាប្រយោជន៍ដល់សហគមន៍ក្នុងតំបន់ លើប្រធានបទនានាមានដូចជាការអប់រំសង្គម សិទ្ធិមនុស្ស និងសុខភាព ជាពិសេសសម្រាប់ស្ត្រីនិងកុមារ។ ក្រសួងព័ត៌មាននៅបន្តធ្វើការជាមួយប្រព័ន្ធផ្សព្វផ្សាយឯកជនដើម្បីផ្តល់ព័ត៌មានប្រកបដោយគុណភាព និងទាន់ពេលវេលាជូនដល់ប្រជាជនទូទាំងប្រទេស ក្នុងន័យគាំទ្រដល់អាទិភាពអភិវឌ្ឍជាតិ របស់រាជរដ្ឋាភិបាល ។ របាយការណ៍ព្រាង ដែលក្រសួងបរិស្ថានបានរៀបរៀង ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ បានបង្ហាញថា បញ្ហាប្រែប្រួលអាកាសធាតុកំពុងក្លាយជាឧបសគ្គដ៏ធំចំពោះការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។ នាពេលកន្លងទៅថ្មីៗនេះ កិច្ចប្រជុំកំពូលលើកទី២០របស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុនៅទីក្រុងលីមាប្រទេសប៉េរូបានចាត់ថ្នាក់កម្ពុជា រួមជាមួយប្រទេសឥណ្ឌា និងហ្វីលីពីនស្ថិតក្នុងចំណោមប្រទេសដែលមានសន្ទស្សន៍ហានិភ័យអាកាសធាតុខ្ពស់។ ដូច្នេះការទទួលបានព័ត៌មានស្តីពីហានិភ័យនិងការគម្រាមកំហែង ពីការប្រែប្រួលអាកាសធាតុមានតួនាទីសំខាន់ក្នុងការរួមចំណែកគាំទ្រភាពបន្សាំនិងការកាត់បន្ថយហានិភ័យនិងការគម្រាមកំហែងសម្រាប់សង្គមជាតិទាំងមូល នៃព្រះរាជាណាចក្រកម្ពុជា ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនេះ ត្រូវបានកសាងឡើងស្របនឹងគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍ របស់ក្រសួង ស្របទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ និងការឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រដើម្បីទប់ទល់នឹងការប្រែប្រួលអាកាសធាតុ។

តាងនាមក្រសួងព័ត៌មានខ្ញុំសូមថ្លែងអំណរគុណជូនចំពោះថ្នាក់ដឹកនាំ ក្រុមការងារ និងសមាជិកទាំងអស់ ដែលកន្លងមកបានប្រឹងប្រែងបំពេញការងារ ប្រកបដោយការប្តេជ្ញាចិត្តក្នុងការរៀបចំកសាងផែនការសកម្មភាពនេះ ។ ផែនការសកម្មភាពនេះ ពិតជាព្រឹត្តិការណ៍សំខាន់ ដែលគាំទ្រកិច្ចអភិវឌ្ឍវិស័យព័ត៌មាននៅកម្ពុជាដោយកំណត់នូវសកម្មភាពសំខាន់ៗជាអាទិភាពដែលអាចប្រែក្លាយទៅជាកម្មវិធីនិងគម្រោងនានាដើម្បីអនុវត្ត ។ ការប្រើប្រាស់ធនធានថវិកាសម្រាប់អនុវត្តសកម្មភាពទាំងឡាយទាំងពួងគឺជាគន្លឹះសំខាន់ដែលនាំទៅរកភាពជោគជ័យ ក្នុងការអនុវត្តផែនការសកម្មភាពសម្រាប់វិស័យព័ត៌មានហើយក៏មានសារៈសំខាន់ រួមចំណែកអនុវត្តឲ្យបានជោគជ័យ នូវផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា ។ ឆ្លៀតឱកាសនេះខ្ញុំសូមថ្លែងអំណរគុណ ដល់គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ព្រមទាំងក្រសួងបរិស្ថាន ដែលបានដឹកនាំការងារឆ្លើយតបនឹង

ការប្រែប្រួលអាកាសធាតុ តាមរយៈការគាំទ្រជាថវិកា និងបច្ចេកទេសទទួលបានពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០១៥

**រដ្ឋមន្ត្រីក្រសួងព័ត៌មាន**

ខៀវ កាញារីទ្ធ

# សេចក្តីថ្លែងអំណរគុណ

ការរៀបចំផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (២០១៥-២០១៨) គឺជាលទ្ធផលនៃការប្តេជ្ញាចិត្តនិងការគាំទ្រខាងនយោបាយពីរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាការគាំទ្រជាប្រចាំពីឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន ដើម្បីបង្កើតក្រុមការងារបច្ចេកទេសស្តីពី ការប្រែប្រួលអាកាសធាតុសម្រាប់ក្រសួងព័ត៌មាន ។ ក្រុមការងារនេះមានមន្ត្រីតំណាងមកពីអគ្គនាយកដ្ឋានជំនាញទាំង៥ ចំណុះក្រសួងព័ត៌មានដើម្បីរៀបចំផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ។ ការចូលរួមបែបនេះបានផ្តល់នូវគុណប្រយោជន៍និងបង្កើតបាននូវភាពប្រទាក់ក្រឡាគ្នានៃផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ជាមួយផែនការនានារបស់ក្រសួងដែលមានស្រាប់ ហើយថែមទាំងឆ្លើយតបទៅនឹងកិច្ចការអាទិភាពថ្នាក់ជាតិទៀតផង។

**តួនាទីរបស់ក្រុមការងាររួមមាន ៖**

- ការស្រាវជ្រាវ តាក់តែងគោលនយោបាយយុទ្ធសាស្ត្រ ឯកសារគតិយុត្តិកម្មវិធីផែនការគម្រោងទាក់ទិននឹងការប្រែប្រួលអាកាសធាតុ ។
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីសិក្សាតាក់តែង និងអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលនយោបាយយុទ្ធសាស្ត្របញ្ញត្តិ ផែនការ កម្មវិធី និងគម្រោង ស្តីពីការប្រែប្រួលអាកាសធាតុ ដើម្បីឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍសហសវត្សរ៍កម្ពុជាជាពិសេសទាក់ទិននឹងការកាត់បន្ថយភាពក្រីក្រ និងនិរន្តរភាពបរិស្ថាន ។
- លើកអនុសាសន៍ ស្តីពីផលប៉ះពាល់និងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុជូនថ្នាក់ដឹកនាំក្រសួងដើម្បីសម្រេច ។
- រួមគ្នាតាមដានបញ្ហាជាសកលនៃការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ដល់ សេដ្ឋកិច្ចសង្គម ហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច ជនជាតិភាគតិចនិងវិស័យផ្សេងទៀត ។
- ចែករំលែកព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ និងវិធានការឆ្លើយតបតាមវិស័យ ។
- សម្របសម្រួលនិងប្រើប្រាស់ធនធានថវិកាពិសេសថវិកាជំនួយដើម្បីគាំទ្រការសិក្សាការតាក់តែងនិងអនុវត្តគោលនយោបាយ ។
- តាមដាន និងវាយតម្លៃកម្មវិធីស្តីពីការប្រែប្រួលអាកាសធាតុ ដែលផលិតដោយអង្គភាពជំនាញរបស់ក្រសួងព័ត៌មាន ។

ជាទីបញ្ចប់ខ្ញុំសូមថ្លែងអំណរគុណ ចំពោះការគាំទ្ររបស់ម្ចាស់ជំនួយតាមរយៈសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា មានដូចជា កម្មវិធីអភិវឌ្ឍសហប្រជាជាតិ សហភាពអឺរ៉ុប និងទីភ្នាក់ងារសហប្រតិបត្តិការនិងអភិវឌ្ឍអន្តរជាតិស៊ុយអែត ដែលបានផ្តល់កិច្ចសហប្រតិបត្តិការ ការយោគយល់និងមិត្តភាពក្នុងដំណើរការកសាងផែនការសកម្មភាពនេះ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ ២០១៥

រដ្ឋលេខាធិការ

និងជាប្រធានក្រុមការងាររៀបចំផែនការឆ្លើយតបនឹង

ការប្រែប្រួលអាកាសធាតុក្រសួងព័ត៌មាន

**ហោ សុគាព**

# មាតិកា


អារម្ភកថា .................... i

សេចក្តីថ្លែងអំណរគុណ .................... iii

មាតិកា .................... v

បញ្ជីពាក្យសរសេរកាត់ .................... vii

សេចក្តីសង្ខេប .................... viii

១. សាវតា .................... 1

២. ចក្ខុវិស័យ .................... 2

៣. បេសកកម្ម .................... 2

៤. ទិសដៅនិងគោលបំណង .................... 2

៥. ក្របខ័ណ្ឌយុទ្ធសាស្ត្រ .................... 3

៥.១ ការវិភាគយុទ្ធសាស្ត្រ .................... 3

៥.២ គោលដៅជាយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រ .................... 7

៦. ផែនការសកម្មភាព .................... 8

៦.១ វិសាលភាពនៃផែនការសកម្មភាព .................... 8

៦.២ តារាងផែនការសកម្មភាព .................... 9

៦.៣ បញ្ហាពាក់ព័ន្ធនឹងថវិកាចំណាយក្នុងក្រសួង .................... 10

៦.៤ ផលប្រយោជន៍រំពឹងទុកពីការអនុវត្តផែនការសកម្មភាព .................... 10

៧. យន្តការគ្រប់គ្រង និងហិរញ្ញប្បទាន .................... 11

៧.១ ការវិភាគទៅលើយន្តការគ្រប់គ្រងនិងហិរញ្ញប្បទាន .................... 11

៧.២ ការវិភាគទៅលើប្រភពនានាដែលមានសក្តានុពល និងទំហំហិរញ្ញវត្ថុសម្រាប់សកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ .................... 12

៧.៣ លទ្ធភាពសម្រាប់បញ្ជ្រៀបការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងយន្តការគ្រប់គ្រង និងហិរញ្ញប្បទាន ..... 12

៨. តាមដាន និងវាយតម្លៃ ..... 12

៨.១ ក្របខ័ណ្ឌសូចនាករ ..... 12

៨.២ ការតាមដាន និងការធ្វើរបាយការណ៍ ..... 13

៩. ច្បាប់និងបញ្ញត្តិ ..... 13

១០. ការសន្និដ្ឋាន ..... 13

ឯកសារយោង ..... 15

ឧបសម្ព័ន្ធ ១ ៖ បញ្ជីសកម្មភាពខ្នាតវែង ..... 16

ឧបសម្ព័ន្ធ ២ ៖ បញ្ជីសកម្មភាពខ្នាតខ្លី ..... 17

ឧបសម្ព័ន្ធ ៣ ៖ តារាងសកម្មភាព ..... 19

## បញ្ជីពាក្យសរសេរកាត់

| | |
|---|---|
| AKP | ទីភ្នាក់ងារសារព័ត៌មានជាតិកម្ពុជា |
| CCAP | ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ |
| CCCA | សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា |
| CCCSP | ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា២០១៤-២០២៣ |
| DP | ដៃគូអភិវឌ្ឍ |
| EU | សហភាពអឺរ៉ុប |
| GHG | ឧស្ម័នផ្ទះកញ្ចក់ |
| KAP | ចំណេះដឹង ឥរិយាបថ និងការអនុវត្ត |
| MoE | ក្រសួងបរិស្ថាន |
| MoInfo | ក្រសួងព័ត៌មាន |
| NCCC | គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុនៅកម្ពុជា |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| RNK | វិទ្យុជាតិកម្ពុជា |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SDP | ផែនការអភិវឌ្ឍតាមវិស័យ |
| SIDA | ទីភ្នាក់ងារសហប្រតិបត្តិការនិងអភិវឌ្ឍអន្តរជាតិ ស៊ុយអែត |
| TV | ទូរទស្សន៍ |
| TVK | ទូរទស្សន៍ជាតិកម្ពុជា |
| UNDP | កម្មវិធីអភិវឌ្ឍសហប្រជាជាតិ |
| UNFCCC | អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |

# សេចក្តីសង្ខេប

នៅក្នុងកិច្ចអភិវឌ្ឍសេដ្ឋកិច្ចជាតិ លទ្ធិប្រជាធិបតេយ្យ វិស័យព័ត៌មានដើរតួយ៉ាងសំខាន់មិនអាចកាត់ផ្តាច់បានហើយកាន់តែសំខាន់ទៅទៀត ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចបែបទំនើប ខណៈដែលពិភពលោកកាន់តែខិតជិតគ្នា ។ ដោយសារព្រះរាជាណាចក្រកម្ពុជាមានកំណើនសេដ្ឋកិច្ចខ្លាំង តួនាទីនៃការចែករំលែកព័ត៌មាន និងតួនាទីរបស់ប្រព័ន្ធព័ត៌មាន កាន់តែមានសារៈសំខាន់ក្នុងការធ្វើឲ្យសង្គមកម្ពុជាស្គាល់តែភាពជោគជ័យនិងរុងរឿង ។ ក្រសួងព័ត៌មានគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍសហសវត្សរ៍កម្ពុជានិងចក្ខុវិស័យ២០៣០ គឺការចាកចេញពីក្រុមប្រទេសមានការលូតលាស់តិចតួច និងប្រែក្លាយកម្ពុជាឲ្យទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ ។

រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំគោលនយោបាយចាំបាច់មួយចំនួន ផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើ ។ គោលនយោបាយមួយក្នុងចំណោមគោលនយោបាយនានា ដើម្បីទប់ស្កាត់គ្រោះមហន្តរាយធម្មជាតិ និងផ្តល់ឱកាសជាច្រើននោះ គឺផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ ដែលជាការឆ្លើយតបទៅនឹងភាពស្មុគស្មាញ និងភាពមិនប្រាកដប្រជានៃហានិភ័យ មកការប្រែប្រួលអាកាសធាតុនិងការគម្រាមកំហែងលើកំណើនសេដ្ឋកិច្ចរបស់កម្ពុជា ជីវភាពរស់នៅនិងការប្រព្រឹត្តទៅនៃប្រព័ន្ធបរិស្ថាន ។ ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ អនុញ្ញាតឲ្យក្រសួង-ស្ថាប័នពាក់ព័ន្ធអនុវត្តយុទ្ធសាស្ត្រទៅជាផែនការសកម្មភាព និងប្រតិបត្តិការលើផែនការអភិវឌ្ឍតាមវិស័យ។

របាយការណ៍អភិវឌ្ឍមនុស្សកម្ពុជាឆ្នាំ២០១១ បានចាត់ទុកប្រព័ន្ធផ្សព្វផ្សាយ ជាតួអង្គសំខាន់ក្នុងកិច្ចការព័ត៌មាននិងទិន្នន័យ ទាក់ទងជាមួយការប្រែប្រួលអាកាសធាតុ។ ក្រសួងបរិស្ថានរាយការណ៍ថាការផ្សព្វផ្សាយព័ត៌មានទាន់ពេលនិងចំហេតុការណ៍គឺជាកត្តាសំខាន់ដែលអាចជួយប្រជាពលរដ្ឋឆ្លើយតបនឹងធាតុអាកាសប្រែប្រួល។ តួនាទីប្រព័ន្ធព័ត៌មានកាន់តែមានសារៈសំខាន់នៅពេលដែលពលរដ្ឋកម្ពុជាជាង៨០%ជាអ្នកប្រើប្រាស់ប្រព័ន្ធនេះ ហើយប្រព័ន្ធសោតទស្សន៍ក៏ជាប្រភពព័ត៌មានគួរទុកចិត្តបានបំផុត។

ដោយមានការគាំទ្រខាងបច្ចេកទេសពីក្រសួងបរិស្ថាន និងការណែនាំពីគណៈរដ្ឋមន្ត្រី ក្រសួងព័ត៌មានបានបង្កើតក្រុមការងារបច្ចេកទេសឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដើម្បីរៀបចំផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ សម្រាប់ក្រសួងព័ត៌មាន ២០១៥-២០១៨ ដោយបានអនុម័តយុទ្ធសាស្ត្រជាច្រើនពាក់ព័ន្ធនឹងផែនការយុទ្ធសាស្ត្រ ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ ហើយបានផ្សារភ្ជាប់ជាមួយផែនការការងារប្រចាំឆ្នាំរបស់ក្រសួងព័ត៌មានទៀតផង ។ ជាលទ្ធផលរបស់ការប្រជុំពិគ្រោះយោបល់ក្រសួងព័ត៌មាន បានដាក់ចេញសកម្មភាពអាទិភាពចំនួន៥ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដោយមានសំណើថវិកាប្រមាណ៤លាន៣៣០ពាន់ដុល្លារ សម្រាប់អនុវត្តឆ្នាំ២០១៥ ដល់២០១៨ ។ សកម្មភាពទាំងនោះរួមមាន ៖

១.ការកសាងធនធានមនុស្សនិងបង្កើនសមត្ថភាពស្តីពីការប្រែប្រួលអាកាសធាតុក្នុងវិស័យសារព័ត៌មាន ។

២.ផលិតកម្មវិធីផ្សាយសម្រាប់លើកកម្ពស់ការយល់ដឹងស្តីពីការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ ។

៣.ជំរុញដល់អង្គភាពផ្សព្វផ្សាយឯកជន ដើម្បីចូលរួមចំណែកផ្សព្វផ្សាយអំពីការប្រែប្រួលអាកាសធាតុ ផលប៉ះពាល់និងដំណោះស្រាយ ។

៤.ពង្រឹងនិងពង្រីកមធ្យោបាយផ្សព្វផ្សាយ សម្រាប់លើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុទូទាំងប្រទេស ។

៥.ពង្រីកវិសាលភាពផ្សាយរបស់ស្ថានីយវិទ្យុ និងទូរទស្សន៍ជាតិ ដើម្បីសម្រួលដល់សាធារណជនឲ្យទទួលបានព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុដល់តំបន់ងាយរងគ្រោះ ។

ផលប្រយោជន៍ដែលនឹងទទួលបានពីសកម្មភាពទាំងឡាយដូចបានលើកឡើងខាងលើ វានឹងរួមចំណែកលើកកម្ពស់ការយល់ដឹងជាសាធារណៈស្តីអំពីការប្រែប្រួលអាកាសធាតុ និងវិធានការឆ្លើយតបដើម្បីបន្សាំជាមួយអាកាសធាតុថ្មីនិងកាត់បន្ថយ "កាបូនហ្ទិតព្រីន" ។ សូចនាករណ៍នៃផែនការសកម្មភាពស្តីពី ការប្រែប្រួលអាកាសធាតុ របស់ក្រសួងព័ត៌មាន នឹងរួមចំណែកទៅក្នុងសូចនាករណ៍របស់ផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិលើវិស័យព័ត៌មាន និងភូមិ-ឃុំមួយចំនួនដែលទទួលរងគ្រោះ ពីការប្រែប្រួលអាកាសធាតុ ។ ក្រុមការងារបច្ចេកទេសឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់ក្រសួងព័ត៌មាន នឹងផ្តល់ជាតុចូល(របាយការណ៍)ទៅនាយកដ្ឋានហិរញ្ញវត្ថុនិងផែនការ ដែលជាអង្គភាពរាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ក្រុមការងារបច្ចេកទេសឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់ក្រសួងព័ត៌មាននឹងដើរតួនាទីកណ្តាលមួយដើម្បីសម្របសម្រួល និងអនុវត្តផែនការសកម្មភាពនេះរួមទាំងសកម្មភាពនិងគម្រោងផ្សេងៗ ពាក់ព័ន្ធជាមួយអង្គភាពនានាក្នុងក្រសួង និងជាមួយក្រសួងនានា។ ក្នុងរយៈពេលខ្លី ក្រុមការងារបច្ចេកទេសឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់ក្រសួងព័ត៌មានដោយមាន កិច្ចសហការជាមួយនឹងធនធានប្រើប្រាស់ក្នុង និងក្រៅក្រសួង ដែលមានសមត្ថភាពអនុវត្តផែនការសកម្មភាពបានជោគជ័យ ។ ហើយក្នុងរយៈពេលវែង ដើម្បីធានាបានថា ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ បន្តអនុវត្តទៅអនាគត ក្នុងផែនការការងារប្រចាំឆ្នាំ និងការរៀបចំថវិកាក្រសួងឲ្យកាន់តែរលូន ។ តួនាទីរបស់ ក្រុមការងារបច្ចេកទេសឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់ក្រសួងព័ត៌មាន គួរចូលរួមក្នុងការរៀបចំថវិកាផែនការការងារប្រចាំឆ្នាំ ឲ្យបានឆាប់រហ័សតាមតែអាចធ្វើទៅបាន។

សរុបសេចក្តីមក ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់ក្រសួងព័ត៌មាន គឺជាផែនការសកម្មភាពលើកដំបូងបង្អស់របស់ក្រសួង ក្នុងការឆ្លើយតបនឹងការគម្រាមកំហែងនិងឱកាសនានា បណ្តាលមកពីការប្រែប្រួលអាកាសធាតុ។

## ១. សាវតា

*រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសអនុវត្ត ផែនការយុទ្ធសាស្ត្រកម្ពុជាឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ២០១៤-២០២៣ ហើយបានដាក់បញ្ចូលផែនការនេះទៅក្នុង ផែនការអភិវឌ្ឍយុទ្ធសាស្ត្រថ្នាក់ជាតិ ២០១៤-២០១៨ ដើម្បីចង្អុលបង្ហាញនូវការគម្រាមកំហែងពីការប្រែប្រួលអាកាសធាតុហើយផែនការនេះក៏បានរួមចំណែកដល់កិច្ចប្រឹងប្រែងរបស់ពិភពលោក ក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ។* CCCSP *គឺជាក្របខ័ណ្ឌការងារធំទូលាយឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ហើយបានអនុញ្ញាតឲ្យស្ថាប័នក្រសួងពាក់ព័ន្ធនានា អភិវឌ្ឍយុទ្ធសាស្ត្រការងារជាច្រើន ដើម្បីប្រែក្លាយយុទ្ធសាស្ត្រនានានៃ*CCCSP *ទៅជាផែនការសកម្មភាព ។ ក្នុងអំឡុងពេលកសាងផែនការ*CCCSP*នេះ ក្រសួងចំនួន៩ បានកសាងផែនការសកម្មភាពយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ តាមវិស័យរៀងៗខ្លួន និងបានបំពេញការងារក្នុងផែនការសកម្មភាពយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដើម្បីគាំទ្រ* SDP *។ ក្រសួងពាក់ព័ន្ធផ្សេងទៀត ត្រូវការដាក់បញ្ចូលនូវការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុង* SDP *របស់ក្រសួងទាំងនោះ ដើម្បីរួមចំណែកកាត់បន្ថយហានិភ័យនៃការប្រែប្រួលអាកាសធាតុ និងចូលរួមអនុវត្ត*CCCSP*ឲ្យបានជោគជ័យ ព្រោះ*CCCSP*ចែងថា "បំផុសលើកទឹកចិត្តក្រសួងទាំងអស់ឲ្យកសាង CCCSP ហើយចូលរួមក្នុងដំណើរការCCCSPនេះ" ។* CCCSP *មានចក្ខុវិស័យគាំទ្រកិច្ចអភិវឌ្ឍប្រកបដោយនិរន្តរភាព និងគាំទ្រសង្គមមួយដែលមានចំណេះដឹងនៅកម្ពុជាដែលក្នុងនោះប្រព័ន្ធសារព័ត៌មានមានតួនាទីមួយសំខាន់ណាស់ក្នុងការសម្រេចឲ្យបាននូវចក្ខុវិស័យនេះ ។ របាយការណ៍ស្តីពីការអភិវឌ្ឍមនុស្សកម្ពុជា២០១១ បានគូសបញ្ជាក់ថា ប្រព័ន្ធព័ត៌មាន គឺជាតួអង្គសំខាន់ក្នុងការកសាងព័ត៌មាន និងទិន្នន័យស្តីពីការប្រែប្រួលអាកាសធាតុ* (RGC 2011) *។ ប្រព័ន្ធព័ត៌មាន (ទាំងបោះពុម្ព និងសោតទស្សន៍) មានសក្តានុពលពង្រីកការយល់ដឹងជាសាធារណៈ ស្តីពីការប្រែប្រួអាកាសធាតុនិងប្រមូលទស្សនៈព័ត៌មានរួមទាំងឥរិយាបថនានាចំពោះបញ្ហានៃការប្រែប្រួលអាកាសធាតុនៅកម្ពុជា ។ ការយល់ដឹងជាសាធារណៈ ស្តីពីការប្រែប្រួលអាកាសធាតុ នាំឲ្យមានការចូលរួមជាសាធារណៈ និងមានឥទ្ធិពលច្រើនថែមទៀតទៅលើអ្នកធ្វើគោលនយោបាយ ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ ។ នៅពេលដែលបច្ចេកវិទ្យាសារគមនាគមន៍កំពុងរីកចម្រើន ប្រព័ន្ធព័ត៌មានក៏កំពុងមានតួនាទីថ្មី ក្នុងការកសាងការយល់ដឹងជាសាធារណៈ ។*

*នៅឆ្នាំ២០១១ ក្រសួងបរិស្ថានបានធ្វើការស្ទង់មតិស្តីពី*KAP *ហើយបានរកឃើញថា ការផ្សព្វផ្សាយព័ត៌មានទាន់ពេលវេលា និងសមស្របជាមួយស្ថានការណ៍ គឺជាការងារមានសារៈសំខាន់ ក្នុងការជួយប្រជាពលរដ្ឋឆ្លើយតបនឹងធាតុអាកាស ដែលកំពុងតែប្តូរផ្លាស់* (MoE, 2011) *។ ដូច្នេះតួនាទីប្រព័ន្ធព័ត៌មានក្នុងការផ្សព្វផ្សាយព័ត៌មានជូនប្រជាជនដែលងាយរងហានិភ័យ និងមនុស្សទូទៅ ក៏មានចំណែកក្នុងកិច្ចប្រឹងប្រែងកាត់បន្ថយផលប៉ះពាល់នៃព្រឹត្តិការណ៍ធាតុអាកាសអាក្រក់បំផុត ។ តួនាទីនេះកាន់តែមានសារៈសំខាន់ ព្រោះថាប្រជាជនកម្ពុជាជាង៨០% ជាអ្នកប្រើប្រាស់ព័ត៌មាន ហើយប្រព័ន្ធសោតទស្សន៍ គឺជាប្រភពព័ត៌មានដែលគេទុកចិត្តបំផុត ។ មនុស្សភាគច្រើនមើលទូរទស្សន៍ និងស្តាប់វិទ្យុផ្សាយសម្លេង ហើយស្ទើរគ្រប់គ្នាមានទូរស័ព្ទដៃប្រើប្រាស់ ។ ទោះជាយ៉ាងនេះក្តី របាយការណ៍ដដែលនេះក៏បានត្អូញត្អែរ*

ពីការពិតដែរថា ប្រព័ន្ធព័ត៌មាននៅកម្ពុជាបានយកចិត្តទុកដាក់តិចតួច លើការប្រែប្រួលអាកាសធាតុ ដែលប្រការនេះបានតម្រូវឲ្យមានការកសាងសមត្ថភាពសម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ។ ក្រសួងព័ត៌មាន (MoInfo) គឺជាស្ថាប័នរដ្ឋាភិបាលដែលមានសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននៅកម្ពុជា ហើយមានប្រព័ន្ធផ្សព្វផ្សាយដូចជាទីភ្នាក់ងារសារព័ត៌មានជាតិកម្ពុជា ទូរទស្សន៍ជាតិកម្ពុជា វិទ្យុជាតិកម្ពុជា នៅទូទាំងប្រទេស (MoInfo, 2014) ជាមួយមធ្យោបាយខាងលើនេះ ក្រសួងព័ត៌មាន មានលទ្ធភាពច្រើនក្នុងការរួមចំណែកចង្អុលបង្ហាញបញ្ហាប្រែប្រួលអាកាសធាតុនៅកម្ពុជា ។ ក្រសួងព័ត៌មាន ស្ថិតលើទីតាំងប្រសើរបំផុត ដើម្បីប្រតិបត្តិសកម្មភាពសារគមនាគមន៍នានាកំពុងប្រកួតប្រជែងគ្នា ដែលអាចជួយដល់យុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងការអប់រំដោយប្រយោល ជាពិសេសតាមរយៈប្រព័ន្ធផ្សព្វផ្សាយមហាជន និងសារគមនាគមន៍លើអន្តរវិស័យ(MoE, 2012) ។ CCSAPសម្រាប់ក្រសួងព័ត៌មាន ត្រូវបានរៀបចំ និងដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍរបស់ក្រសួង។ យុទ្ធសាស្ត្រនានារបស់ក្រសួងផ្តោតការយកចិត្តទុកដាក់លើ ការប្រែប្រួលអាកាសធាតុ ក្នុងនោះមានផែនការសកម្មភាពសង្ខេបធ្ងន់លើការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងដាក់បញ្ចូលទៅក្នុងផែនការការងារប្រចាំឆ្នាំរបស់ក្រសួង ។ ការកសាង CCSAPសម្រាប់ក្រសួងព័ត៌មាន បានប្រតិបត្តិតាមគោលនយោបាយរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។ រីឯក្រសួង បរិស្ថាន គឺជាស្ថាប័នផ្តល់ការណែនាំខាងបច្ចេកទេស ។ CCSAPសម្រាប់ក្រសួងព័ត៌មានដាក់ចេញនូវ ចក្ខុវិស័យ បេសកកម្ម ទិសដៅ និងគោលបំណងក្របខ័ណ្ឌយុទ្ធសាស្ត្រ និងការវិភាគហើយនឹងផែនការ សកម្មភាព ។ គោលបំណងជាយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រនៃCCSAPសម្រាប់ក្រសួងព័ត៌មានត្រូវបាន អនុម័តស្របតាមស្មារតីនៃCCCSP ។ ផែនការសកម្មភាពអនុវត្តយុទ្ធសាស្ត្រនានា ដែលមានសេចក្តីលម្អិត ស្តីពីសកម្មភាពទាំងឡាយនោះ ។ ជាមួយគ្នានេះដែរឯកសារនេះ បានបង្ហាញពីយន្តការគ្រប់គ្រង និងផ្តល់ហិរញ្ញប្បទាន ព្រមទាំងក្របខ័ណ្ឌតាមដាននិងវាយតម្លៃ។

## ២. ចក្ខុវិស័យ

ផ្អែកលើCCCSP ជាចក្ខុវិស័យជាតិនៃការប្រែប្រួលអាកាសធាតុគឺ "***កម្ពុជាអភិវឌ្ឍឆ្ពោះទៅរកសង្គមមួយ ដែលបៃតងបញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ សមធម៌ ចីរភាព និងពឹងផ្អែកចំណេះដឹងជាគោល***"។

## ៣. បេសកកម្ម

ជាទូទៅបេសកកម្មកាត់បន្ថយ និងបន្សាំការប្រែប្រួលអាកាសធាតុគឺ "បង្កើតក្របខ័ណ្ឌថ្នាក់ជាតិមួយ អនុញ្ញាតឲ្យសាធារណជន វិស័យឯកជន អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍមានវត្តមានចូលរួមទាំងអស់គ្នាក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដើម្បីគាំទ្រការអភិវឌ្ឍប្រកបដោយចីរភាព"។

## ៤. ទិសដៅនិងគោលបំណង

- កាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជន ជាពិសេសក្រុមអ្នកដែលងាយរងគ្រោះបំផុត និងប្រព័ន្ធសំខាន់ៗ ( ធម្មជាតិ និង សង្គម ) បណ្តាលមកពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ។

- បង្វែរទៅរកមាគ៌ាអភិវឌ្ឍបៃតង តាមរយៈការលើកកម្ពស់ការអភិវឌ្ឍបញ្ចេញកាបូនតិច និង បច្ចេកវិទ្យាពាក់ព័ន្ធ។
- លើកកម្ពស់ការយល់ដឹង និងការចូលរួមរបស់សាធារណជន ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួល អាកាសធាតុ។

## ៥. ក្របខ័ណ្ឌយុទ្ធសាស្ត្រ

### ៥.១ ការវិភាគយុទ្ធសាស្ត្រ

***គោលនយោបាយជាតិស្តីពីព័ត៌មាន***

*គោលនយោបាយជាតិ ស្តីពីព័ត៌មានយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣នៃរាជរដ្ឋាភិបាល កម្ពុជា បានចាត់ទុកការអភិវឌ្ឍវិស័យព័ត៌មាន និងបច្ចេកវិទ្យាសារគមនាគមន៍ ជាគោលនយោបាយសំខាន់ មួយ (RGC, 2014) ។ វិស័យព័ត៌មាន និងបច្ចេកវិទ្យាសារគមនាគមន៍ ជាមធ្យោបាយលើកកម្ពស់កិច្ច អភិវឌ្ឍធនធានមនុស្ស និងជាទូទៅពង្រីកអន្តរកម្មសាធារណៈ ។ ដើម្បីគាំទ្រគោលនយោបាយនេះ ក្រសួងព័ត៌មានបានដាក់ចេញនូវគោលនយោបាយជាអាទិភាពចំនួន៣ ៖*

- *ពង្រីកការផ្សព្វផ្សាយកម្មវិធីព័ត៌មានប្រកបដោយគុណភាព អប់រំ និងកំសាន្ត ដល់ប្រជាពលរដ្ឋ ពី ៨៥%ទៅ៩៥% នៅទូទាំងប្រទេស ។*
- *លើកទឹកចិត្តការប្រើសិទ្ធិសារព័ត៌មាននិងសេរីភាពនៃការបញ្ចេញមតិ ដែលស្របនឹងគោលការណ៍ លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស នីតិរដ្ឋ និងការពារសិទ្ធិមនុស្សនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស ។*
- *រួមចំណែកថែរក្សា និងលើកស្ទួយវប្បធម៌និងប្រពៃណី ដើម្បីលើកកម្ពស់អត្តសញ្ញាណជាតិ និង កិត្តិនាមប្រទេសជាតិលើឆាកអន្តរជាតិ ។*

***ការព្យាករណ៍ និងបញ្ហាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ***

*ផ្នែកនេះគឺជាការដកស្រង់ចេញពីCCCSP (RGC, 2013) សម្រាប់អ្នកអានស្វែងយល់អំពីការ ព្យាករណ៍ និងបញ្ហាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។*

***ការព្យាករណ៍អាកាសធាតុ***

- *ក្នុងរយៈពេលកន្លងមកសីតុណ្ហភាពនៅកម្ពុជាបានកើនឡើងរួចទៅហើយ ។ និន្នាការនេះត្រូវបាន ព្យាករណ៍ថានឹងបន្តកើនឡើងដោយសីតុណ្ហភាពមធ្យមប្រចាំខែនឹងកើនឡើងចន្លោះពី០,០១៣°C ដល់០,០៣៦°Cក្នុងមួយឆ្នាំៗរហូតដល់ឆ្នាំ២០៩៩ អាស្រ័យលើទីតាំង ដោយមានអត្រាកំណើន ខ្ពស់នៅតំបន់ទំនាប។*
- *ទោះបីពុំទាន់មានភស្តុតាងច្បាស់លាស់ អំពីផលប៉ះពាល់លើកម្ពស់ទឹកភ្លៀងក្តី ក៏ការព្យាករណ៍ នានាបានបញ្ជាក់ថា ជារួមកម្ពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំនឹងកើននៅប្រទេសកម្ពុជា ។ ការ ព្យាករណ៍របបទឹកភ្លៀងប្រចាំរដូវ បង្ហាញពីនិន្នាការកើនឡើងរវាងខែមិថុនា និងសីហានៅតំបន់ ពាយព្យ និងនិន្នាការថយចុះនៅភាគឦសាន។*

- របាយការណ៍វាយតម្លៃលើកទី៤របស់ក្រុមការងារអន្តររដ្ឋាភិបាល ស្តីពីការប្រែប្រួលអាកាសធាតុ បានប៉ាន់ស្មានថាកម្ពស់ទឹកសមុទ្រនៅក្នុងតំបន់នេះនឹងកើនឡើងទៅតាមកម្រិតដូចតទៅៈ រហូតដល់ឆ្នាំ២០៩០ធៀបនឹងឆ្នាំ ១៩៨០-១៩៩៩ កម្ពស់ទឹកសមុទ្រនឹងកើនឡើងពី០,១៨ ម៉ែត្រ ដល់ ០,៤៣ម៉ែត្រ នៅក្រោមសេណារីយ៉ូអត្រាបញ្ចេញឧស្ម័នកម្រិតទាប ០,២១-០,៥២ម៉ែត្រ នៅក្រោម សេណារីយ៉ូអត្រាបញ្ចេញឧស្ម័នកម្រិតមធ្យមនិង០,២៣-០,៥៦ម៉ែត្រ នៅក្រោមសេណារីយ៉ូអត្រា បញ្ចេញឧស្ម័នកម្រិតខ្ពស់ ។ នេះមានន័យថា នៅក្រោមសេណារីយ៉ូ អត្រាបញ្ចេញឧស្ម័នកម្រិត ខ្ពស់ អត្រាកំណើនកម្ពស់ទឹកសមុទ្រនឹងមាន០,៥៦ម៉ែត្រ ដែលអាចបង្កឱ្យមានការជន់លិចជា អចិន្ត្រៃយ៍លើផ្ទៃដីទំហំប្រមាណ២៥.០០០ហិកតា នៅតាមតំបន់ឆ្នេរកម្ពុជា ក្នុងរយៈពេល ៩០ឆ្នាំ ខាងមុខ ។

**<u>ឥទ្ធិពលពាក់ព័ន្ធ</u>**

- កំណើនសីតុណ្ហភាព ទំនងជាបង្កឲ្យមានឥទ្ធិពលមកលើផលិតភាពកសិកម្ម ។ យោងតាមវិទ្យាស្ថានស្រាវជ្រាវពូជស្រូវ បានបង្ហាញថាទិន្នផលស្រូវនឹងថយចុះ១០% សម្រាប់កំណើនសីតុណ្ហភាព១°C ធៀបនឹងសីតុណ្ហភាពអប្បបរមានៅរដូវដាំដុះ (ពេលយប់) នៅក្នុងរដូវប្រាំង។
- គម្រោងបន្ស៊ាំ និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុក្នុងតំបន់មេគង្គ បានបង្ហាញថា ខេត្តនៅរយៈកម្ពស់ខ្ពស់នៃកម្ពុជានៅរដូវវស្សានឹងមានភ្លៀងច្រើនជាងមុន ដោយឡែកនៅរដូវប្រាំងវិញមានសភាពស្ងួតហែងដែលអាចរាំងការផលិតកាហ្វេ និងកៅស៊ូ ។
- ឆ្នេរសមុទ្រកម្ពុជាប្រវែង៤៣៥គ.ម. ងាយរងគ្រោះដោយសារកំណើនកម្ពស់ទឹកសមុទ្រ និងផលប៉ះពាល់ធ្ងន់ធ្ងរពីខ្យល់ព្យុះទីហ្វុងកាន់តែញឹកញាប់ នៅក្រោមការព្យាករណ៍អាកាសធាតុនាពេលអនាគត ។ បញ្ហានេះ អាចមានឥទ្ធិពលមកលើសក្តានុពលភ្ញៀវទេសចរ និងបង្កឲ្យមានការហូរច្រោះផងដែរ ហើយខ្យល់បក់ខ្លាំងបណ្តាលឲ្យខូចខាតដល់លំនៅស្ថាននៅតំបន់ឆ្នេរ ។
- ក្នុងករណីដែលផ្ទៃដីស្រោចស្រពគ្រប់គ្រាន់ មានតែ៧% ទៅ៨% កម្ពុជាប្រហែលជាពិបាកសម្រេចបានកំណើនកសិផល៥%ក្នុងមួយឆ្នាំៗ ដើម្បីសម្រេចបានចំណុចដៅ ក្នុងការបង្កើនការនាំចេញផលិតផលកសិកម្មនៅឆ្នាំ២០៣០ ក្រោមលក្ខខណ្ឌប្រែប្រួលអាកាសធាតុ (ដូចជាគ្រោះរាំងស្ងួត) ជាពិសេស សម្រាប់ដំណាំសំខាន់ៗមួយចំនួន ដូចជាដំណាំស្រូវ ប្រសិនបើគ្មានការវិនិយោគក្នុងការពង្រីកប្រព័ន្ធស្រោចស្រពទេនោះ ។
- យោងតាមកម្រងទិន្នន័យគ្រោះមហន្តរាយអន្តរជាតិ (EM-DAT) គ្រោះធម្មជាតិនៅឆ្នាំ២០១១ បានបង្កការខូចខាតសេដ្ឋកិច្ចប្រមាណ៤,៣% នៃផលិតផលក្នុងស្រុកសរុប ។ ទឹកជំនន់ដែលបង្កដោយការប្រែប្រួលអាកាសធាតុ ត្រូវបានព្យាករណ៍ថានឹងកើតមានកាន់តែញឹកញាប់និងធ្ងន់ធ្ងរជាងមុនជាពិសេសនៅតំបន់ទំនាបកណ្តាល ។ នៅពេលដែលតំបន់ឆ្នេរនឹងរងឥទ្ធិពលពីខ្យល់ព្យុះស៊ីក្លូនមកពីមហាសមុទ្រប៉ាស៊ីហ្វិក តំបន់ទំនាបកណ្តាលនឹងរងគ្រោះ ដោយសារទឹកជំនន់ដែលបង្កដោយកំណើនភ្លៀងធ្លាក់ ។ តំបន់ទាំងពីរនេះមានសារៈសំខាន់ណាស់ចំពោះសេដ្ឋកិច្ចជាតិ ដោយសារតែវិភាគទានខ្ពស់ទៅក្នុងសារពើពន្ធទទួលបានពីទេសចរណ៍ សេវាកម្ម សកម្មភាព

នាវាចរណ៍ ការនេសាទ និងផលិតផលកសិកម្ម ។ ជាការចាំបាច់ ត្រូវចាត់វិធានការដើម្បីកាត់បន្ថយ ផលប៉ះពាល់នៃហានិភ័យ និងគ្រោះមហន្តរាយបណ្តាលមកពីប្រែប្រួលអាកាសធាតុ ដើម្បីឲ្យ កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍតាមការរំពឹងទុក ក្នុងកម្មវិធីអភិវឌ្ឍជាតិ ។

- ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់កម្ពុជា នៅមានកម្រិតទាបខ្លាំង បើប្រៀបធៀបនឹងតួលេខមធ្យម នៅថ្នាក់តំបន់និងពិភពលោក ។ យោងតាមរបាយការណ៍ជាតិលើកទី២ ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ បរិមាណឧស្ម័នផ្ទះកញ្ចក់សរុប ដែលកម្ពុជាបញ្ចេញនៅឆ្នាំ២០០០ មានប្រមាណ៤៧,៦លានតោន ហើយវិស័យព្រៃឈើ បានស្រូបយកចំនួនប្រមាណ៤៨លានតោន គិតជាសមមូលឧស្ម័នកាបូនិក ។ នៅក្នុងអំឡុងពេលដូចគ្នានេះ វិស័យដឹកជញ្ជូនប្រើប្រាស់ឥន្ធនៈ ហ្វូស៊ីលច្រើនជាងគេ បន្ទាប់មកគឺការផលិតអគ្គិសនីលំនៅដ្ឋាន និងវិស័យឧស្សាហកម្ម ។ កម្ពុជាត្រូវបង្កើនការផលិតថាមពល សំដៅជំរុញសកម្មភាពឧស្សាហកម្ម ទន្ទឹមនឹងការកែលម្អប្រសិទ្ធភាពថាមពលនៅក្នុងវិស័យដឹកជញ្ជូននិងវិស័យលំនៅដ្ឋាន ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ។ នៅក្នុងដំណាក់កាលបង្កើនការផ្គត់ផ្គង់នេះ ចាំបាច់ត្រូវចាប់ផ្តើមគិតគូរអំពីការបញ្ចូលប្រភពថាមពលកកើតឡើងវិញ ទៅក្នុងផលិតកម្មថាមពល។

## ការយល់ដឹងជាសាធារណៈស្តីពីការប្រែប្រួលអាកាសធាតុ

ដោយសារតែការប្រែប្រួលអាកាសធាតុជាការប្រឈមដ៏ធ្ងន់ធ្ងរមួយ ទាមទារឲ្យមានការចូលរួមដ៏សកម្មពីសំណាក់សមាជិកទាំងអស់នៃសង្គមបច្ចេកទេសទាន់សម័យ ដើម្បីបង្កើតកម្មវិធីយល់ដឹងជាសាធារណៈ និងសកម្មភាពគ្រប់ផ្នែកក្នុងស្រទាប់ប្រជាពលរដ្ឋ ដែលមានសារៈសំខាន់បំផុតឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ។ ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ អាស្រ័យព័ត៌មានសម្បូរបែបគ្របដណ្តប់ប្រធានបទផ្សេងពីគ្នា និងមានប្រភពផ្សេងពីគ្នា ។ នៅកម្ពុជាមនុស្សតិចណាស់យល់ដឹងអំពីភាពស្មុគស្មាញនេះនិងបញ្ហាពាក់ព័ន្ធ ស្តីពីការប្រែប្រួលអាកាសធាតុ ទោះបីការប្រែប្រួលអាកាសធាតុបាននិងកំពុងក្លាយជាកម្មវត្ថុនៃកង្វល់ក៏ដោយ (RGC, 2011) ។ ស្ថាប័នរដ្ឋជាច្រើនអង្គការក្រៅរដ្ឋាភិបាលនានា និងអ្នកស្រាវជ្រាវ បានប្រឹងប្រែងលើកឡើងនូវការយល់ដឹងជាសធារណៈ ស្តីពីការប្រែប្រួលអាកាសធាតុ ។ ការស្រាវជ្រាវស្តីពី KAP (ចំណេះដឹង ឥរិយាបថ និងការអនុវត្តន៍) ធ្វើឡើងដោយក្រសួងបរិស្ថាន បានបង្ហាញថា ប្រជាជនកម្ពុជាមួយចំនួនតូចយល់ពីមូលដ្ឋានវិទ្យាសាស្ត្រនៃការប្រែប្រួលអាកាសធាតុ (MoE, 2011) ។ របាយការណ៍ដដែលនេះ រកឃើញផងដែរថា ទោះបីប្រជាជនកម្ពុជាទទួលស្គាល់នូវលក្ខខណ្ឌនៃការប្រែប្រួលអាកាសធាតុ និងការឡើងកម្តៅជាសកលក៏ដោយ ក៏ប្រជាជនភាគច្រើនខ្វះការយល់ដឹងស៊ីជម្រៅលើពាក្យបច្ចេកទេសស្តីពីការប្រែប្រួលអាកាសធាតុព្រមទាំងបុព្វហេតុ និងឥទ្ធិពលរបស់វា ។ ដោយមានការព្យាករណ៍លើការប្រែប្រួលអាកាសធាតុដែលក្លាយជាការពិត នោះប្រជាជនកម្ពុជានឹងជួបប្រទះផលប៉ះពាល់ទាំងឡាយនោះមុនគេ ។ កម្មវិធីបំផុសការយល់ដឹងនានា របស់ស្ថាប័នរដ្ឋដៃគូអភិវឌ្ឍ អង្គការក្រៅរដ្ឋាភិបាល និងអ្នកស្រាវជ្រាវភាគច្រើនផ្តោតលើការបណ្តុះបណ្តាល និងសកម្មភាពបំផុសការយល់ដឹង ដែលភាគច្រើនសំដៅលើមន្ត្រីរាជការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសហគមន៍

ងាយរងហានិភ័យ (CCCA, 2014) និងសម្ភារព្រមទាំងការបណ្តុះបណ្តាលបំផុសការយល់ដឹង ស្តីពីការប្រែប្រួលអាកាសធាតុ ត្រូវបានចុះផ្សាយឬផ្សព្វផ្សាយបានតិចតួចតាមបណ្តាញព័ត៌មានសាធារណៈ ទាក់ទិននឹងបញ្ហាគោលនយោបាយ និងទិដ្ឋភាពវិទ្យាសាស្ត្រ ។ ដូច្នេះឃើញថា វាមានគម្លាតធំធេងក្នុងការបំផុសការយល់ដឹងជាទូទៅដែលការស្រាវជ្រាវ KAP រកឃើញថា ចំនួនប្រជាជនកម្ពុជាតិចតួចណាស់យល់ដឹងអំពីមូលដ្ឋានវិទ្យាសាស្ត្រនៃការប្រែប្រួលអាកាសធាតុ ។ ដើម្បីចង្អុលបង្ហាញគម្លាតនេះ នាយកដ្ឋាននៃការប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន បានសហការជាមួយក្រសួងព័ត៌មាន បណ្តុះបណ្តាលជាបឋម ប្រព័ន្ធព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ (CCCA, 2013) ។ ជាងនេះទៅទៀត នាយកដ្ឋាននេះក៏មានសកម្មភាពផ្សព្វផ្សាយ ដើម្បីបំផុសការយល់ដឹង ស្តីពីការប្រែប្រួលអាកាសធាតុតាមរយៈព្រឹត្តិការណ៍ជាតិ បណ្តាញអ៊ីនធើណិត ដូចជាហ្វេសប៊ុក និងគេហទំព័រដាដើម និងបណ្ណាល័យពាក់ព័ន្ធ ។ ទោះបីអ្នកអនុវត្តគម្រោងស្តីពីការប្រែប្រួលអាកាសធាតុនានា បានប្រឹងប្រែងលើកកម្ពស់ការយល់ដឹងស្តីពីការប្រែប្រួលអាកាសធាតុក៏ដោយ ក៏ប្រព័ន្ធព័ត៌មានមានតួនាទីសំខាន់ណាស់ ក្នុងការផ្សព្វផ្សាយ និងចែករំលែកសារ ស្តីពីការប្រែប្រួលអាកាសធាតុ ស្តីពីវិទ្យាសាស្ត្រនិងគោលនយោបាយ និងស្តីអំពីការការពារគ្រោះមហន្តរាយជូនសាធារណជនឲ្យបានទូលំទូលាយ និងទាន់ពេលវេលា ។ របាយការណ៍សារគមនាគមន៍ថ្នាក់ជាតិ ទាំងពីរលើកក្នុងក្របខ័ណ្ឌ UNFCCC សង្កត់ធ្ងន់លើតួនាទីដ៏សំខាន់របស់ប្រព័ន្ធព័ត៌មាន ក្នុងការលើកកម្ពស់ការយល់ដឹង ស្តីពីការប្រែប្រួលអាកាសធាតុ ដោយសារតែទូរទស្សន៍ និងវិទ្យុផ្សាយសម្លេង គឺជាប្រភពសាមញ្ញបំផុត នៃការទទួលបានព័ត៌មាន (MoE, 2002) និង (2010)។

**តួនាទីប្រព័ន្ធព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ**

របាយការណ៍ស្តីពីការអភិវឌ្ឍមនុស្សកម្ពុជា២០១១ (RGC, 2011) បានឲ្យតម្លៃលើប្រព័ន្ធព័ត៌មានជាតួអង្គដ៏សំខាន់ ក្នុងការកសាងព័ត៌មាន និងទិន្នន័យ ស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា ។ ប្រព័ន្ធព័ត៌មានមានតួនាទីសំខាន់ ក្នុងការផ្សព្វផ្សាយបញ្ជូនព័ត៌មានដល់សាធារណជនទូទៅ ស្តីពីធាតុអាកាស ទឹកភ្លៀង និងហានិភ័យពីខ្យល់ព្យុះនានា ។ ពួកគេអាចបំផុសការយល់ដឹងជាសាធារណៈ ហើយជាអ្នកត្រួតពិនិត្យមើលតួអង្គដទៃទៀត ដែលពាក់ព័ន្ធការងារឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ។ ប្រព័ន្ធផ្សព្វផ្សាយដែលមានប្រជាប្រិយភាព ដូចជាសារព័ត៌មានបោះពុម្ពទូរទស្សន៍ វិទ្យុផ្សាយសម្លេង និងអ៊ីនធើណិត មានលទ្ធភាពគ្របដណ្តប់គ្រប់វិស័យទូទាំងប្រទេស និងប្រជាពលរដ្ឋគ្រប់ស្រទាប់ ។ ប្រហែលគ្នានេះដែរ ការស្រាវជ្រាវ KAP រកឃើញថា ប្រព័ន្ធវិទ្យុផ្សាយសម្លេង និងទូរទស្សន៍ គឺជាប្រភពព័ត៌មានដ៏មានប្រជាប្រិយភាពបំផុត ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ។ ការផ្សព្វផ្សាយព័ត៌មានទាន់ហេតុការណ៍ អាចធ្វើឲ្យប្រជាជនឆ្លើយតបនឹងការផ្លាស់ប្តូរធាតុអាកាស ដូច្នេះវាមិនមែនគ្រាន់តែផ្សាយឲ្យដឹងនោះទេ (MoE, 2011) ។ ជាការពិតណាស់ថា ប្រព័ន្ធព័ត៌មានដើរតួសំខាន់ ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ។ ការប្រមូលព័ត៌មាន ស្តីពីការប្រែប្រួលអាកាសធាតុមិនបានគ្រប់ជ្រុងជ្រោយ កំពុងតែចាក់ឫសក្នុងប្រព័ន្ធព័ត៌មាននិងមធ្យោបាយសោតទស្សន៍ ។ ក្នុងប្រទេសកំពុងអភិវឌ្ឍ អ្នកសារព័ត៌មានភាគច្រើន មានជំនាញវិជ្ជាជីវៈទូទៅ មិនទទួលបានការបណ្តុះបណ្តាលគ្រប់គ្រាន់ខាងវិទ្យាសាស្ត្រឬក៏

បរិស្ថាន ពិសេសវិស័យឯកទេសនានា ដូចជាការប្រែប្រួលអាកាសធាតុ (Kakonge, 2011) ។ ការប្រឈមមួយទៀតរបស់ប្រព័ន្ធសោតទស្សន៍គឺកម្លាំងផ្សាយ ។ ប្រជាជនភាគច្រើននៅកម្ពុជារស់នៅជនបទ ដែលនៅទីនោះពុំមានសេវាអគ្គិសនី និងសេវាសារព័ត៌មានបោះពុម្ព ។ មានតែវិទ្យុផ្សាយសម្លេង អាចផ្សាយដល់អ្នកស្តាប់បានយ៉ាងទូលំទូលាយ ។ សរុបសេចក្តីមក ថវិកាសម្រាប់ប្រមូល និងផលិតផ្សាយចែករំលែកព័ត៌មាននៅមានកម្រិត ។ ដូច្នេះ ការកសាងផែនការសកម្មភាព និងយុទ្ធសាស្ត្រ គឺត្រូវប្រើប្រាស់ធនធាន និងមធ្យោបាយរបស់ក្រសួងព័ត៌មាន តាមរយៈការដាក់បញ្ចូលផែនការនៃការប្រែប្រួលអាកាសធាតុទៅក្នុងសកម្មភាពនានា ដែលមានស្រាប់ (គោលនយោបាយអាទិភាព)។

**គោលនយោបាយអាទិភាព**

ក្រសួងព័ត៌មានបានកំណត់អាទិភាពមួយចំនួន ដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ដើម្បីអនុវត្តក្នុងអាណត្តិទី៥នៃរាជរដ្ឋាភិបាលកម្ពុជា ២០១៤-២០១៨ (RGC, 2014) ។

- អាទិភាពទី១: ការផលិតកម្មវិធីលើប្រធានបទអប់រំទូលំទូលាយ ស្តីពីសង្គម ច្បាប់ យេនឌ័រ និងកុមារ និងកម្មវិធីយល់ដឹង សម្រាប់មជ្ឈដ្ឋានទូទៅនិងសហគមន៍ ។
- អាទិភាពទី២: ការអភិវឌ្ឍធនធានមនុស្ស ដោយលើកកម្ពស់ការបណ្តុះបណ្តាលបច្ចេកទេស និងការកែលម្អជំនាញនៅមូលដ្ឋានថ្នាក់ក្រោមជាតិ ដើម្បីពង្រីកប្រព័ន្ធសោតទស្សន៍ទូទាំងប្រទេស និងផលិតកម្មវិធីអប់រំផ្សេងៗ ។
- និងអាទិភាពចុងក្រោយ គឺក្រសួងព័ត៌មាន មានគម្រោងសហការជាមួយផ្នែកឯកជន ដើម្បីពង្រីកតំបន់គ្របដណ្តប់ប្រព័ន្ធសោតទស្សន៍ លើកកម្ពស់កម្មវិធីអប់រំ និងកែលម្អគុណភាពកម្មវិធីព័ត៌មាន ។

### ៥.២ គោលដៅជាយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP) ត្រូវបានប្រកាសអនុវត្តនាខែវិច្ឆិកា ឆ្នាំ២០១៣ ដោយ **សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។ CCCSP បានកំណត់គោលបំណងយុទ្ធសាស្ត្រចំនួន៩ រួមជាមួយយុទ្ធសាស្ត្រចំនួន៦២ បង្កើតបានជាក្របខ័ណ្ឌទូលំទូលាយមួយ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា ។ ការពិគ្រោះយោបល់នៅក្រសួងព័ត៌មាន បានកំណត់គោលដៅជាយុទ្ធសាស្ត្រទី៥ និងយុទ្ធសាស្ត្រមួយចំនួនរបស់ CCCSP ជាការងារដែលមានការពាក់ព័ន្ធច្រើនទៅនឹងសមត្ថកិច្ចរបស់ក្រសួងព័ត៌មាន ។ គោលដៅជាយុទ្ធសាស្ត្រទី៥ : ការកែលម្អសមត្ថភាព ចំណេះដឹង និងការយល់ដឹង ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

**យុទ្ធសាស្ត្រ**

ក. ពង្រឹងការអនុវត្តតាមមាត្រា ៦ នៃ UNFCCC ស្តីពីការអប់រំ ការបណ្តុះបណ្តាល ការយល់ដឹង ការចូលរួម និងការទទួលបានព័ត៌មានដោយប្រជាពលរដ្ឋ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ។

ខ. ពង្រឹងមធ្យោបាយមានស្រាប់ ដើម្បីបំផុសការយល់ដឹង ស្តីពីការប្រែប្រួលអាកាសធាតុ តាមរយៈ អ្នកផ្តល់សេវារដ្ឋាភិបាល គ្រូបង្រៀន អ្នកសារព័ត៌មាន សេវាបន្ត អ្នកដឹកនាំសាសនា និងមនុស្សចាស់ក្នុងសហគមន៍។

គ. កសាងកម្មវិធីយល់ដឹងតាមគោលដៅ គឺសំដៅលើក្រុមមនុស្សដែលងាយរងគ្រោះ ដែលមានស្ត្រីភេទ, កុមារ, យុវជន, និងជនជាតិភាគតិច។

ឃ. សម្រួលឲ្យសាធារណជនទទួលបានព័ត៌មាន ស្តីពីការប្រែប្រួលអាកាសធាតុ តាមរយៈវិទ្យុផ្សាយសម្លេង ទូរទស្សន៍ កាសែត បច្ចេកវិទ្យាគេហទំព័រ និងទូរគមនាគមន៍ ព្រមទាំងមានសម្ភារផ្សព្វផ្សាយតាមគោលដៅ។

ង. ធ្វើឲ្យផ្នែកឯកជនចាប់អារម្មណ៍លើការគម្រាមកំហែង និងឱកាសនៃការប្រែប្រួលអាកាសធាតុ (គាំទ្របច្ចេកវិទ្យា ហិរញ្ញប្បទាន ការផ្ទេរបច្ចេកវិទ្យា) ហើយបង្កើតជាដៃគូឯកជនសាធារណៈដើម្បីទំនាក់ទំនងគ្នា។

## ៦. ផែនការសកម្មភាព

ក្រសួងព័ត៌មាន បានកំណត់សកម្មភាពគន្លឹះ ដើម្បីអនុវត្តយុទ្ធសាស្ត្រ ដែលអនុម័តចេញពី CCCSP ។ ផ្នែកនេះ រៀបរាប់លម្អិតពីវិសាលភាពនៃសកម្មភាព និងម៉ាទ្រីសនៃផែនការ និងពិពណ៌នាពីបញ្ហាពាក់ព័ន្ធ នៃថវិកាចំណាយសម្រាប់អន្តរាគមន៍ក្នុងការប្រែប្រួលអាកាសធាតុ និងផលប្រយោជន៍ទទួលបានពីការអនុវត្ត។

### ៦.១ វិសាលភាពនៃផែនការសកម្មភាព

ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់ក្រសួងព័ត៌មាន បានកំណត់ពេលវេលាភ្ជាប់ជាមួយដំណើរការកសាងផែនការរបស់ក្រសួង ។ សកម្មភាពទាំងឡាយត្រូវបានបែងចែកជា៣ប្រភេទ ។

- ប្រភេទ១ ថ្លឹងថ្លែងឡើងវិញពីសកម្មភាពដែលបានគ្រោង និងមានស្រាប់ ដើម្បីកែសម្រួលសំដៅរួមចំណែកដល់ការបន្សាំ និងការកាត់បន្ថយផលប៉ះពាល់ ។ ចំណុចនេះអាចបន្ថែមសកម្មភាពសាកល្បងនានា ។
- ប្រភេទ២ កែសម្រួលសកម្មភាពមានស្រាប់ ដោយបង្ហាញបញ្ហាពាក់ព័ន្ធជាមួយអាកាសធាតុ ឬបន្ថែមការកាត់បន្ថយផលប៉ះពាល់ ។
- ប្រភេទ៣ សកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុដែលមានការតាំងចិត្តខ្ពស់ ។

បញ្ជីសកម្មភាពខ្នាតវែង (ឧបសម្ព័ន្ធ ១) ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ត្រូវបានស្នើឡើងដោយអង្គភាពនានារបស់ក្រសួង ។ បញ្ជីខ្នាតវែងនេះ ត្រូវបានផ្តល់អាទិភាព ឲ្យប្រើវិធីសាស្ត្រវិភាគគ្រប់លក្ខណៈសម្បត្តិ ដែលនាំឲ្យមានបញ្ជីសកម្មភាពខ្នាតខ្លី (ឧបសម្ព័ន្ធ ២) ។ (ឧបសម្ព័ន្ធ ៣) ផ្តល់សេចក្តីលម្អិតអំពីសកម្មភាពនីមួយៗ ។

### ៦.២ តារាងផែនការសកម្មភាព

ក្នុងតារាងនេះមានការប៉ាន់ស្មានថវិកា អង្គភាពទទួលខុសត្រូវ និងប្រភេទសកម្មភាព ស្របនឹងសកម្មភាពអាទិភាពនីមួយៗ (ឧបសម្ព័ន្ធ ២) ។

| ល.រ | សកម្មភាព | ថវិកាប៉ាន់ស្មាន (គិតជាពាន់ដុល្លារ) | | | | |
|---|---|---|---|---|---|---|
| | | 2015 | 2016 | 2017 | 2018 | Total |
| ១ | កសាងធនធានមនុស្ស និងពង្រឹកសមត្ថភាព ស្តីពីការប្រែប្រួលអាកាសធាតុផ្នែកព័ត៌មាន <u>ភាគរយថវិកាពាក់ព័ន្ធនឹងហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុៈ ១០០%</u> | ១៥០ | ១៥០ | | | ៣០០ |
| ២ | ផលិតកម្មវិធីបំផុស ការយល់ដឹង ស្តីពីការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ <u>ភាគរយថវិកាពាក់ព័ន្ធនឹងហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុៈ ៧៥%</u> | ៤០០ | ៣០០ | ៣០០ | ២០០ | ១២០០ |
| ៣ | ស្នើដល់ប្រព័ន្ធព័ត៌មានឯកជន ចូលរួមផ្សាយពីការប្រែប្រួលអាកាសធាតុ ផលប៉ះពាល់ និងដំណោះស្រាយ <u>ភាគរយថវិកាពាក់ព័ន្ធ នឹងហិរញ្ញវត្ថុ ប្រែប្រួលអាកាសធាតុៈ ៥០%</u> | ១០០ | ១០០ | ១៥០ | ១៥០ | ៥០០ |
| ៤ | ពង្រីកមធ្យោបាយសោតទស្សន៍ បំផុសការយល់ដឹងស្តីពីការប្រែប្រួលអាកាសធាតុ ពេញផ្ទៃប្រទេស <u>ភាគរយថវិកាពាក់ព័ន្ធ នឹងហិរញ្ញវត្ថុ ប្រែប្រួលអាកាសធាតុៈ ១០%</u> | ៥០០ | ៥០០ | ៥០០ | ៥០០ | ២.០០០ |
| ៥ | ពង្រីកតំបន់គ្របដណ្តប់ ការផ្សាយ វិទ្យុនិង ទូរទស្សន៍ជាតិ ឲ្យសាធារណជន ទទួលបានព័ត៌មាន ស្តីពីការប្រែប្រួលអាកាសធាតុ <u>ភាគរយថវិកាពាក់ព័ន្ធនឹងហិរញ្ញវត្ថុ ប្រែប្រួលអាកាសធាតុៈ ១០%</u> | ១០០ | ១០០ | ៦៥ | ៦៥ | ៣៣០ |
| | សរុប | ១.២៥០ | ១.១៥០ | ១.០១៥ | ៩១៥ | ៤.៣៣០ |
| | ថវិកាពាក់ព័ន្ធសរុបសម្រាប់ហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុ (យោងតាមវិធីសាស្ត្រក្នុងក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ) | | | | | ១.៦៨៣ |

## ៦.៣ បញ្ហាពាក់ព័ន្ធនឹងថវិកាចំណាយក្នុងក្រសួង

ការប៉ាន់ស្មានថវិកាសរុបចំណាយ ក្នុងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់ក្រសួងព័ត៌មាន គឺ ៤លាន៣៣០ពាន់ដុល្លារ សម្រាប់ឆ្នាំ២០១៥-២០១៨ ។ ចំនួនភាគច្រើននៃថវិកា (ឬ៥៥%នៃ៤លាន៣៣០ពាន់ដុល្លារ) នឹងត្រូវចំណាយសម្រាប់ពីរឆ្នាំដំបូង សម្រាប់ការអភិវឌ្ឍ ធនធានមនុស្ស និងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តមួយចំនួន ។ បើតាមកម្មវិធីវិនិយោគរំកិល២០១៥-២០១៧ ក្រសួងព័ត៌មាន ស្នើអនុវត្តគម្រោងចំនួន៧ ក្នុងនោះមានគម្រោងពីរកំពុងតែអនុវត្ត ដោយមានថវិកាសរុបចំនួន៦.១២១.០០០ដុល្លារ ។ កម្មវិធីសំខាន់គឺ ពង្រីកការផ្សាយទៅកាន់តំបន់ជនបទ និងកសាងស្ថានីយវិទ្យុថ្មីសម្រាប់ប្រព័ន្ធ FM និង AM ។ វាច្បាស់ណាស់ថា គម្រោងនេះគឺជាថវិកាវិនិយោគទទួលបានពីរាជរដ្ឋាភិបាលកម្ពុជា ។ ក្រសួងក៏បានចរចាលើគម្រោង៥ទៀត តាមអាទិភាពបែបនេះគឺ

(១) បង្កើនសមត្ថភាពAKP

(២) សាងសង់រោងពុម្ពថ្មីជាមួយនឹងឧបករណ៍សម្ភារៈថ្មី

(៣) បង្កើតស្ថានីយទូរទស្សន៍ថ្នាក់ក្រោមជាតិចំនួន៩ (តាមខេត្តនិងរាជធានី)

(៤) សាងសង់អគារថ្មីៗ បំពាក់ឧបករណ៍សម្ភារថ្មី សម្រាប់ស្ថានីយផ្សាយវិទ្យុជាតិកម្ពុជា

(៥) បង្កើតប្រព័ន្ធព័ត៌មាន ជាមួយប្រទេសអាស៊ាន ។ ថវិកាសរុបសម្រាប់គម្រោងនេះគឺ ៨,៤លានដុល្លារ។

## ៦.៤ ផលប្រយោជន៍រំពឹងទុកពីការអនុវត្តផែនការសកម្មភាព

ផលប្រយោជន៍ដែលរំពឹងថានឹងទទួលបានពីការអនុវត្តផែនការសកម្មភាព ការឆ្លើយតប នឹងការប្រែប្រួលអាកាសធាតុសម្រាប់ក្រសួងព័ត៌មាន គឺការលើកកម្ពស់ការយល់ដឹងជាសាធារណៈ ស្តីពីការប្រែប្រួល អាកាសធាតុ ព្រមទាំងវិធានការឆ្លើយតប ពោលគឺការបន្សាំជាមួយការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់... និងការកាត់បន្ថយជាតិកាបូន ។

ទី១ ផែនការសកម្មភាពនេះ នឹងកែលម្អធនធានមនុស្ស ក្នុងវិស័យព័ត៌មាននៅកម្ពុជាដើម្បីរាយការណ៍និងផ្សាយព័ត៌មាន ស្តីពីការប្រែប្រួលអាកាសធាតុ ។

ទី២ ផែនការនេះនឹងផលិតបាននូវឯកសារផ្សព្វផ្សាយឲ្យយល់ដឹង ដូចជាបទយកការណ៍ និងវីដេអូខ្លីៗ សម្រាប់ប្រើប្រាស់ក្នុងកម្មវិធីផ្សព្វផ្សាយ ឲ្យយល់ដឹងពីការប្រែប្រួលអាកាសធាតុ ។

ទី៣ សាធារណជននឹងបានយល់ដឹងអំពីបញ្ហា ដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការផ្សាយពីប្រព័ន្ធព័ត៌មាននានា ។

ទី៤ ស្ថានីយផ្សាយបន្តនៅតាមខេត្ត ទទួលបានការបំពាក់ឧបករណ៍សម្ភារទាន់សម័យដែលនាំឲ្យការផ្សាយកាន់តែ មានសមត្ថភាព និងទាន់ពេលវេលា ។ និយាយរួម ការពង្រីកកម្លាំងផ្សាយគ្របដណ្តប់ទៅកាន់តំបន់ងាយរងគ្រោះ គឺជាវិធានការឆ្លើយតបទៅនឹងមហន្តរាយ ដែលកើតឡើងដោយសារអាកាសធាតុ និងជួយផ្តល់ចំណេះដឹងបានច្រើនជាងមុនដល់ប្រជាជន ស្តីពីការប្រែប្រួលអាកាសធាតុ ។ ការចំណាយសម្រាប់សកម្មភាពនីមួយៗមានសរសេរក្នុង Action Fiche (សូមអានឧបសម្ព័ន្ធ២) ។

## ៧. យន្តការគ្រប់គ្រង និងហិរញ្ញប្បទាន

### ៧.១ ការវិភាគទៅលើយន្តការគ្រប់គ្រងនិងហិរញ្ញប្បទាន

ក្រសួងព័ត៌មាន មានអគ្គនាយកដ្ឋានចំនួន៥ គឺអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និង អគ្គនាយកដ្ឋានជំនាញចំនួន៤ ដូចជាអគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍ អគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា ។ អគ្គនាយកដ្ឋាននីមួយៗមាននាយកដ្ឋានជំនាញ ដែលគ្របដណ្តប់ទិដ្ឋភាពជាច្រើនក្នុងវិស័យព័ត៌មាន ។ លើសពីនេះ ក្រសួងព័ត៌មាន ក៏នៅមានអង្គភាពបីទៀត គឺអធិការកិច្ច មជ្ឈមណ្ឌលបណ្តុះបណ្តាល និងវិក្រឹតការវិជ្ជាជីវៈសារព័ត៌មាន និងសវនកម្មហិរញ្ញវត្ថុៗរីឯនៅថ្នាក់ក្រោមជាតិ ក្រសួងមានមន្ទីរព័ត៌មានគ្រប់ខេត្ត និងរាជធានី ដូចក្នុងរចនាសម្ព័ន្ធក្រសួងព័ត៌មានខាងក្រោម៖



**៧.២ ការវិភាគទៅលើប្រភពនានាដែលមានសក្ដានុពល និងទំហំហិរញ្ញវត្ថុសម្រាប់សកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ**

CCAP មានសកម្មភាព៥ ដែលត្រូវការថវិកាសរុប៤លាន៣៣០ពាន់ដុល្លារ សម្រាប់រយៈពេល ៤ឆ្នាំ ។ ថវិកាជិត៥០% ចំណាយលើការពង្រីកមធ្យោបាយផ្សព្វផ្សាយទូទាំងប្រទេស ដើម្បីលើកកម្ពស់ការយល់ដឹងស្តីពីការប្រែប្រួលអាកាសធាតុ ។ ក្រសួងរំពឹងថា នឹងស្វែងរកធនធានថវិកាមួយចំនួនណានោះពីម្ចាស់ជំនួយ ដែលមានស្រាប់ ដោយលើកឡើងជាផែនការស្តីពីការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងដំណាក់កាលរៀបចំនិងបង្ហាញគម្រោង ។ ធនធានសម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុផ្សេងទៀត នឹងអាចដកចេញពី មូលនិធិប្រទេសមានការអភិវឌ្ឍតិចតួចបំផុត និងមូលនិធិអាកាសធាតុបៃតង ។ ថវិកាចំណាយលើហេដ្ឋារចនាសម្ព័ន្ធ អាចឡើងឬចុះ អាស្រ័យលើសេណារីយ៉ូហិរញ្ញប្បទាននៃការប្រែប្រួលអាកាសធាតុទាបឬខ្ពស់។

**៧.៣ លទ្ធភាពសម្រាប់បញ្ជៀបការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងយន្តការគ្រប់គ្រង និងហិរញ្ញប្បទាន**

ទុនវិនិយោគក្នុងក្របខ័ណ្ឌក្រសួងព័ត៌មាន ត្រូវគ្រប់គ្រងដោយឡែក តាមការកំណត់ដោយគម្រោង ។ ប្រសិនបើពុំមានយន្តការសម្របសម្រួលរឹងមាំទេ នោះគួរអនុវត្តជាទម្រង់ការស្តង់ដារ ក្នុងនោះមានការប្រែប្រួលអាកាសធាតុតាមលក្ខណៈវិនិច្ឆ័យ សម្រាប់អត្តសញ្ញាណកម្ម និងការអនុវត្តនៃគម្រោង ។ ការិយាល័យគ្រប់គ្រងគម្រោង អាចត្រូវបង្កើតឡើង ហើយការិយាល័យនេះមានតួនាទី ដាក់ចេញនូវស្តង់ដារ សម្រាប់គម្រោងទាំងអស់ ។ សកម្មភាពអាទិភាពគួរគប្បីសិក្សាស្រាវជ្រាវ ដើម្បីកំណត់សកម្មភាពសមស្របដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ។ សកម្មភាព CCAP ជាច្រើន ត្រូវបានផ្សារភ្ជាប់ជាមួយគម្រោងនានា ដែលដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគសាធារណៈរបស់ក្រសួង ហើយអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នឹងដាក់បញ្ចូលសកម្មភាពថ្មីៗ ទៅក្នុងកម្មវិធីវិនិយោគ សាធារណៈរបស់ក្រសួង ។ អគ្គនាយកដ្ឋាននេះមាន៥នាយកដ្ឋាន គឺ រដ្ឋបាលទូទៅ បុគ្គលិក ផែនការ គណនេយ្យ និងហិរញ្ញវត្ថុ គ្រប់គ្រងសម្ភារនិងទ្រព្យរដ្ឋ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ។

**៨. តាមដាន និងវាយតម្លៃ**

**៨.១ ក្របខ័ណ្ឌសូចនាករ**

NSDP ២០១៤-២០១៨ បង្ហាញថា ក្រសួងព័ត៌មាន កំពុងតាមដានសូចនាករនានា ពាក់ព័ន្ធវិស័យព័ត៌មាន ដែលលេចចេញពីបណ្តាញព័ត៌មានរដ្ឋ និងឯកជន ។ បណ្តាញព័ត៌មានរដ្ឋគ្របដណ្តប់សូចនាករ៣ ពោលគឺ ទូរទស្សន៍ វិទ្យុផ្សាយសម្លេង និងទីភ្នាក់ងារសារព័ត៌មាន ។ បណ្តាញព័ត៌មានឯកជនគ្របដណ្តប់សូចនាករ៥ ពោលគឺ ទូរទស្សន៍ ទូរទស្សន៍ខ្សែកាប (រាជធានី/ខេត្ត) វិទ្យុផ្សាយសម្លេង បណ្តាញព័ត៌មានបោះពុម្ព (កាសែត ព្រឹត្តិបត្រ ទស្សនាវដ្តី ជាភាសាខ្មែរនិងបរទេស) និងរោងពុម្ព ។ ជាមួយសូចនាករស្តីពី ទូរទស្សន៍ និងវិទ្យុផ្សាយសម្លេង (ចំនួនស្ថានីយ និងកម្លាំងផ្សាយ) ក្រសួងអាចដឹងពីវិសាលភាពនៃការផ្សាយ ហើយក៏ដឹងដែរថា ប្រជាពលរដ្ឋអាចទទួលបានព័ត៌មានកម្រិតណា ។ សូចនាករនៃផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ សម្រាប់ក្រសួងព័ត៌មាន នឹងរួម

ចំណែកដល់ក្របខ័ណ្ឌថ្នាក់ជាតិតាមដាន និងវាយតម្លៃ ស្តីពីការប្រែប្រួលអាកាសធាតុ ដែលកំពុងរៀបចំដោយក្រសួងបរិស្ថាន ។ លើសពីនេះសូចនាករទាំងនោះ ក៏ផ្សារភ្ជាប់ជាមួយ NSDP ស្តីពីការប្រែប្រួលអាកាសធាតុនិង "ចំនួនឃុំដែលងាយរងគ្រោះ ដោយសារការប្រែប្រួលអាកាសធាតុ" ផងដែរ ។

### ៨.២ ការតាមដាន និងការធ្វើរបាយការណ៍

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ដែលមាន៥នាយកដ្ឋានគឺ រដ្ឋបាលទូទៅ បុគ្គលិក ផែនការគណនេយ្យនិងហិរញ្ញវត្ថុ គ្រប់គ្រងសម្ភារនិងទ្រព្យរដ្ឋ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នឹងមានតួនាទីសំខាន់ៗជាច្រើន ដូចជានាយកដ្ឋានផែនការ គណនេយ្យនិងហិរញ្ញវត្ថុ មានតួនាទីរៀបចំរបាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍អនុវត្ត ដែលត្រូវបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ក្រុមការងារបច្ចេកទេសឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់ក្រសួង នឹងផ្តល់ធាតុចូលទៅក្នុងសកម្មភាពនានា ស្តីពីការប្រែប្រួលអាកាសធាតុ ទៅនាយកដ្ឋានផែនការគណនេយ្យ និងហិរញ្ញវត្ថុ ។ អង្គភាពសវនកម្មផ្ទៃក្នុងរបស់ក្រសួង មានតួនាទីប្រតិបត្តិលើកិច្ចការសវនកម្មហិរញ្ញវត្ថុផ្ទៃក្នុង ផ្អែកលើការណែនាំពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ៩. ច្បាប់និងបញ្ញត្តិ

ពុំមានតម្រូវការបន្ថែមខាងផ្លូវច្បាប់និងបញ្ញត្តិ ដើម្បីអនុវត្តផែនការសកម្មភាព ស្តីពីការប្រែប្រួលអាកាសធាតុរបស់ក្រសួងព័ត៌មានទេ ។ ទោះជាយ៉ាងនេះក្តី ក៏នៅមានតម្រូវការសម្រាប់រយៈពេលខ្លី ដើម្បីលើកកម្ពស់សមត្ថភាពរបស់ក្រុមការងារបច្ចេកទេស ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់ក្រសួង ដើម្បីធានាឲ្យមានបរិយាកាសអំណោយផល ដល់ការអនុវត្តផែនការសកម្មភាព ឲ្យមានប្រសិទ្ធភាព ។ ការលើកកម្ពស់សមត្ថភាពទី១ គឺការសម្របសម្រួល ប្រកបដោយប្រសិទ្ធភាពជាមួយនាយកដ្ឋានពាក់ព័ន្ធ ព្រមទាំងបណ្តាញព័ត៌មានឯកជន និងទី២ គឺការទំនាក់ទំនងជាពិសេស ជាមួយលេខាធិការដ្ឋានNCCC ក្រសួងបរិស្ថាននិងក្រសួងពាក់ព័ន្ធផ្សេងទៀត ។ ហើយសម្រាប់រយៈពេលវែង តួនាទីរបស់ក្រុមការងារបច្ចេកទេសឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់ក្រសួង គួរធ្វើយ៉ាងណាឲ្យមានការចូលរួមក្នុងដំណាក់កាលដំបូង ក្នុងការរៀបចំផែនការថវិកាប្រចាំឆ្នាំ ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីធានាឲ្យបានថា ការទទួលខុសត្រូវពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ត្រូវបានដាក់ បញ្ចូលក្នុងផែនការការងារប្រចាំឆ្នាំ និងការរៀបចំថវិការបស់ក្រសួង ។ ប្រការនេះអាចតម្រូវឲ្យមានសារាចរណែនាំពីក្រសួង ដើម្បីធានាការចូលរួមពេញលេញ ពីក្រុមការងារបច្ចេកទេសឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់ក្រសួង ក្នុងការកសាងផែនការការងារនិងថវិកាប្រចាំឆ្នាំ ។

## ១០. ការសន្និដ្ឋាន

ផែនការសកម្មភាពស្តីពីការប្រែប្រួលអាកាសធាតុ (CCAP) របស់ក្រសួងព័ត៌មានគឺជាផែនការដំបូងមិនធ្លាប់មានរបស់ក្រសួង ដែលត្រូវបានកសាងឡើង ដើម្បីផ្តល់ការគាំទ្រដល់តួនាទីដ៏សំខាន់របស់ក្រសួង ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ។ តាមការព្យាករណ៍បានឲ្យដឹងថាការប្រែប្រួលអាកាសធាតុនឹងជះឥទ្ធិពលអាក្រក់លើសេដ្ឋកិច្ចរបស់កម្ពុជា ជីវៈចម្រុះ និងជីវភាពរស់នៅរបស់មនុស្ស

រាប់លាននាក់នៅតំបន់ដែលងាយរងគ្រោះ ។ CCAPអាចជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយ ដើម្បីប្រើប្រាស់ធនធានជាតិ និងអន្តរជាតិ ។ ដូច្នេះ ការផលិតសម្ភារទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពផ្អែកលើផែនការសកម្មភាពស្តីពីការប្រែប្រួលអាកាសធាតុ គឺជាជំហានមួយទៀត ក្នុងការប្រើប្រាស់ធនធាន និងសហការជាមួយនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាននិងក្រសួងពាក់ព័ន្ធ ដើម្បីបង្ហាញផែនការសកម្មភាព ស្តីពីការប្រែប្រួលអាកាសធាតុក្នុងព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ (ឧទាហរណ៍ៈ ព្រឹត្តិការណ៍បន្ទាប់បន្សំរបស់ UNFCCC វេទិកាជាតិស្តីពីការប្រែប្រួលអាកាសធាតុ កិច្ចប្រជុំសម្របសម្រួលជាមួយដៃគូអភិវឌ្ឍ) ។ គួររៀបចំសិក្ខាសាលាពីសកម្មភាពនេះ ។ ដំណើរការគន្លឹះដែលមានឥទ្ធិពលលើការប្រើប្រាស់ធនធានក្នុងប្រទេសតាមរយៈផែនការសកម្មភាព ស្តីពីការប្រែប្រួលអាកាសធាតុ គឺត្រូវតែជានាំឲ្យបាននូវការផ្លាស់ប្តូរបន្ទាប់បន្សំក្នុងការផ្តល់ថវិកា ចំពោះក្រសួង និងនាយកដ្ឋាន ព្រមទាំងសកម្មភាពទាំងឡាយណា ដែលបានរួមចំណែកប្រកបដោយប្រសិទ្ធភាពធំបំផុតក្នុងការបន្សាំ និងការកាត់បន្ថយផលប៉ះពាល់ ។ ការវិនិច្ឆ័យគួរផ្អែកលើប្រការខាងក្រោមនេះៈ

- របៀបនៃការរៀបចំថវិកាក្រសួងបានល្អប៉ុនណា សម្រាប់ការប្រែប្រួលអាកាសធាតុ ក្នុងនោះមានការវិភាគ ថាតើថវិកាស្នើឡើងនោះជួយកែលម្អបានកម្រិតណា ដល់ការបន្សាំនិងកាត់បន្ថយផលប៉ះពាល់និងតម្លៃនៃការកែលម្អរបស់ជាតិ ។
- ប្រើប្រព័ន្ធត្រួតពិនិត្យសម្រាប់ការរៀបចំគម្រោង ក្នុងនោះ ការស្នើកម្មវិធីវិនិយោគសាធារណៈ រួមមានសេចក្តីអធិប្បាយអំពីផលប្រយោជន៍ ការបន្សាំ និងការកាត់បន្ថយផលប៉ះពាល់នៃគម្រោងទាំងអស់ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ។ ប្រព័ន្ធត្រួតពិនិត្យ អាចប្រើតាពងសកម្មភាព នៅក្នុងផែនការសកម្មភាពស្តីពីការប្រែប្រួលអាកាសធាតុ ទោះបីការកែប្រែទម្រង់កម្មវិធីវិនិយោគសាធារណៈផ្តោតលើការប្រែប្រួលអាកាសធាតុមានអត្ថប្រយោជន៍ក៏ដោយ ។
- CCCA គឺជាអង្គការសម្របសម្រួលមូលនិធិពហុដៃគូនឹងជួយកិច្ចការទូទៅដល់ក្រសួងក្នុងការស្វែងរកប្រភពផ្តល់មូលនិធិ ការធ្វើគោលនយោបាយបន្ថែម និងការអភិវឌ្ឍសមត្ថភាពសម្រាប់មន្ត្រីក្នុងក្រុមការងារបច្ចេកទេស ស្តីពីការប្រែប្រួលអាកាសធាតុលើវិស័យព័ត៌មាន ។

## ឯកសារយោង


CCCA. (2013). *Annual Progress Report 2013.* Phnom Penh: Cambodia Climate Change Alliance.

CCCA. (2013). *Summary Report and Follow Up Actions: Experience Sharing Workshop for Pilot Climate Change Projects, Sihanooukville, 28-30 January 2013.* Phnom Penh: Cambodia Climate Change Alliance.

CCCA. (2014). *Summary Report and Follow Up Actions: Climate Change Adaptation Learning Event, Battambang City, 4-6 June 2014.* Phnom Penh: Cambodia Climate Change Alliance.

Kakonge, J. O. (2011). The Role of Media in the Climate Change Debate in Developing Countries. *Global Policy Essay.*

MoE. (2002). *Initial National Communication to the UNFCCC.* Ministry of Environment.

MoE. (2010). *(draft) Second National Communication to the UNFCCC.* Ministry of Environment.

MoE. (2011). *Understanding Public Perceptions of Climate Change in Cambodia.* Ministry of Environment.

MoE. (2012). *Climate Change Education and Awareness Guideline.* Ministry of Environment.

MoInfo. (2014). Retrieved from Ministry of Information: http://www.information.gov.kh/

RGC. (2011). *Cambodia Human Development Report 2011. Building Resilience: The Future of Rural Livelihoods in the Face of Climate Change.* Ministry of Environment of Cambodia and UNDP Cambodia.

RGC. (2013). *Cambodia Climate Change Strategic Plan 2014-2023.* Royal Government of Cambodia.

RGC. (2014). *National Strategic Development Plan (NSDP) 2014-2018.* Phnom Penh: Ministry of Planning.

**ឧបសម្ព័ន្ធ ១ ៖ បញ្ជីសកម្មភាពខ្លាតវែង**

បន្ទាប់ពីសិក្ខាសាលាពិគ្រោះយោបល់ នាថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៤ ស្តីពីការកសាងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់ក្រសួងព័ត៌មាន បញ្ជីសកម្មភាពខ្លាតវែងត្រូវបានបង្កើតឡើងដោយពិចារណាលើសកម្មភាពនានា ស្រង់ចេញពីផែនការវិនិយោគសាធារណៈ ២០១៣-២០១៥ របស់ក្រសួងសកម្មភាពចំនួន១៧ត្រូវបានស្នើឡើង ។ (សូមមើលតារាងខាងក្រោម)

| ល.រ | សំណើស្តីពីសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ សម្រាប់ក្រសួងព័ត៌មាន | រយៈពេល |
|---|---|---|
| ១ | ផ្សព្វផ្សាយព័ត៌មានអាកាសធាតុដល់តំបន់ដាច់ស្រយាល | ២០១៥-២០១៨ |
| ២ | បង្កើតដៃគូជាមួយប្រព័ន្ធព័ត៌មានឯកជន ដើម្បីផ្សព្វផ្សាយព័ត៌មានអាកាសធាតុ និងចូលរួមបំផុសការយល់ដឹងពីការប្រែប្រួលអាកាសធាតុ | ២០១៥-២០១៨ |
| ៣ | កសាងសមត្ថភាពស្តីពីការប្រែប្រួលអាកាសធាតុ ដល់អ្នកសារព័ត៌មាន ពិធីករ និងផលិតករ | ២០១៥-២០១៨ |
| ៤ | បង្កលក្ខណៈងាយស្រួលដល់សាធារណជនឲ្យទទួលបានព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុតាមរយៈការពង្រីកតំបន់គ្របដណ្តប់ការផ្សាយរបស់ វិទ្យុនិងទូរទស្សន៍ | ២០១៥-២០១៨ |
| ៥ | ផលិតវីដេអូខ្លី បទយកការណ៍និងភាពយន្តឯកសារ បំផុសការយល់ដឹងស្តីពីការប្រែប្រួលអាកាសធាតុនិងផលប៉ះពាល់ផ្សព្វផ្សាយដល់មហាជន តាមគោលដៅផ្សេងគ្នា | ២០១៦-២០១៨ |
| ៦ | វិទ្យុនិងទូរទស្សន៍ ផលិតកម្មវិធីបំផុសការយល់ដឹងពីការប្រែប្រួលអាកាសធាតុ (បទសម្ភាសន៍ សន្ទនាមតិ សំណួរចម្លើយ) | |
| ៧ | សិក្ខាសាលាបណ្តុះបណ្តាល អ្នកសារព័ត៌មាន ផលិតករ ពិធីករ លើប្រធានបទ ស្តីពីការប្រែប្រួលអាកាសធាតុ | |
| ៨ | បង្កើតគេហទំព័រ និងបណ្តាញសង្គម ផ្សព្វផ្សាយព័ត៌មានស្តីពីការប្រែប្រួល អាកាសធាតុ ជូនសាធារណជន | |
| ៩ | បណ្តុះបណ្តាលគ្រូបង្គោល តាមខេត្ត (មន្ទីរព័ត៌មាន មនុស្សចាស់និងប្រជានភូមិ) | |
| ១០ | ប្រកួតប្រជែងក្នុងចំណោមគ្រូបង្គោលស្តីពីការប្រែប្រួលអាកាសធាតុ (Q&Aស្តីពីសមិទ្ធផល) | |
| ១១ | យុទ្ធនាការផ្សព្វផ្សាយតាមប្រព័ន្ធសារព័ត៌មាននៅតាមសហគមន៍ | |
| ១២ | ផលិតកម្មវិធីស្វែងយល់ជាសាធារណៈ ស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់សហគមន៍នីមួយៗ | |
| ១៣ | ផលិតកម្មវិធីស្វែងយល់ជាសាធារណៈ ស្តីពីការប្រែប្រួលអាកាសធាតុ សម្រាប់ក្រុមមនុស្សគោលដៅផ្សេងគ្នា | |
| ១៤ | ជ្រើសរើសជនបង្គោលចូលរួមផ្សព្វផ្សាយដំណឹងស្តីពីការប្រែប្រួលអាកាសធាតុ | |
| ១៥ | ស្ថានីយវិទ្យុទូរទស្សន៍តាមតំបន់ឆ្ងាយ ចាក់ផ្សាយឡើងវិញ | |

| | | |
|---|---|---|
| ១៦ | រៀបចំនីតិវិធី ដើម្បីឲ្យប្រតិបត្តិករឯកជនផ្សាយកម្មវិធីស្តីពីការប្រែប្រួលអាកាសធាតុ | |
| ១៧ | ឧបត្ថម្ភដល់ប្រព័ន្ធផ្សព្វផ្សាយឯកជនដូចជាឧបករណ៍ សម្ភារបរិក្ខារថវិកា ដើម្បីផ្សព្វផ្សាយពីការប្រែប្រួលអាកាសធាតុ | |

## ឧបសម្ព័ន្ធ ២ ៖ បញ្ជីសកម្មភាពខ្លាតខ្លី

ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ក្រុមការងារបច្ចេកទេសនៃការប្រែប្រួលអាកាសធាតុរបស់ក្រសួងព័ត៌មាន បានប្រារព្ធកិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីផលិតបញ្ជីសកម្មភាពខ្លាតខ្លីដែលមានខ្លឹមសារដូចខាងក្រោមនេះ

| ល.រ | សកម្មភាព | រយៈពេល |
|---|---|---|
| ១ | ការកសាងធនធានមនុស្សនិងបង្កើនសមត្ថភាពស្តីពីការប្រែប្រួលអាកាសធាតុក្នុងវិស័យសារព័ត៌មាន | ២០១៥-២០១៦ |
| ២ | ផលិតកម្មវិធីផ្សាយ សម្រាប់លើកកម្ពស់ការយល់ដឹង ស្តីពីការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ | ២០១៥-២០១៨ |
| ៣ | ជំរុញដល់អង្គភាពផ្សព្វផ្សាយឯកជន ដើម្បីចូលរួមចំណែកផ្សព្វផ្សាយអំពីការប្រែប្រួលអាកាសធាតុ ផលប៉ះពាល់និងដំណោះស្រាយ | ២០១៥-២០១៨ |
| ៤ | ពង្រឹង និងពង្រីកមធ្យោបាយផ្សព្វផ្សាយសម្រាប់លើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុទូទាំងប្រទេស | ២០១៥-២០១៨ |
| ៥ | ពង្រីកវិសាលភាពកម្លាំងផ្សាយរបស់ស្ថានីយវិទ្យុ និងទូរទស្សន៍ជាតិ ដើម្បីសម្រួលដល់សាធារណជន ឲ្យទទួលបានព័ត៌មាន ស្តីពីការប្រែប្រួលអាកាសធាតុដល់តំបន់ងាយរងគ្រោះ | ២០១៥-២០១៨ |

| លក្ខណៈវិនិច្ឆ័យសកម្មភាព | ប្រសិទ្ធភាព | | | | សហផលប្រយោជន៍ | | | កិច្ចការដែលអាចធ្វើបាន | | |
|---|---|---|---|---|---|---|---|---|---|---|
| -<br>-<br>-<br>-<br>-<br>-<br>-<br>-<br>- | កាត់បន្ថយចំណាយលើហានិភ័យអាកាសធាតុ | ការចំណាយសម្រាប់អ្នកទទួលផលប្រយោជន៍ម្នាក់ៗ | ចំនួនអ្នកទទួលផលប្រយោជន៍ | ប្រសិទ្ធភាពចំណាយលើការកាត់បន្ថយ | សេដ្ឋកិច្ច | សង្គម | បរិស្ថាន | ការប្តេជ្ញាចិត្តខាងនយោបាយ | សមត្ថភាព | ងាយអនុវត្ត |
| | -១- ៣ | ០- ៣ | ០-៣ | -១-២ | ០-២ | ០-២ | ០-២ | G/Y/R | G/Y/R | G/Y/R |
| អភិវឌ្ឍធនធានមនុស្សនិងពង្រឹកសមត្ថភាពវិស័យព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ | ១ | ២ | ៣ | ១ | ២ | ២ | ២ | G | Y | Y |
| ផលិតកម្មវិធីលើកកម្ពស់ការយល់ដឹងស្តីពីការប្រែប្រួលអាកាសធាតុនិងផលប៉ះពាល់ | ១ | ៣ | ៣ | ១ | ២ | ២ | ២ | G | Y | Y |
| ស្នើប្រព័ន្ធព័ត៌មានឯកជនចូលរួមផ្សាយប្រធានបទស្តីពីការប្រែប្រួលអាកាសធាតុ ផលប៉ះពាល់និងដំណោះស្រាយ | ១ | ៣ | ៣ | ១ | ២ | ២ | ២ | G | G | Y |
| ពង្រីកមធ្យោបាយផ្សាយដើម្បីលើកកម្ពស់ការយល់ដឹងស្តីពីការប្រែប្រួលអាកាសធាតុនៅទូទាំងប្រទេស | ១ | ៣ | ៣ | ១ | ២ | ២ | ២ | G | G | Y |
| ពង្រីកតំបន់គ្របដណ្តប់ ការផ្សាយវិទ្យុនិងទូរទស្សន៍ ឲ្យពលរដ្ឋទទួលបានព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ | ១ | ២ | ២ | ១ | ២ | ២ | ២ | G | G | G |

**ឧបសម្ព័ន្ធ ៣ ៖ តារាងសកម្មភាព**

| | |
|---|---|
| សកម្មភាព ១ | ការអភិវឌ្ឍធនធានមនុស្សនិងពង្រឹកសមត្ថភាពវិស័យព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ |
| គោលដៅជាយុទ្ធសាស្ត្រ CCCSP | គោលដៅជាយុទ្ធសាស្ត្រទី ៥ ៖ កែលម្អសមត្ថភាព ចំណេះដឹង និងការយល់ដឹង ស្តីពីការប្រែប្រួលអាកាសធាតុ |
| ហេតុផល | យុទ្ធសាស្ត្រចតុកោណ និងកម្មវិធីអភិវឌ្ឍយុទ្ធសាស្ត្រជាតិ ២០១៤-២០១៨ ផ្តោតលើការអភិវឌ្ឍធនធានមនុស្ស វិស័យព័ត៌មានដែលត្រូវលើកកម្ពស់ការបណ្តុះបណ្តាលនិងកែលម្អជំនាញគ្រប់កម្រិត ដើម្បីពង្រីកការផ្សាយនៅទូទាំងប្រទេស និងផលិតកម្មវិធីអប់រំនានា ជាគុណប្រយោជន៍ដល់ប្រទេសជាតិ។<br>ការអភិវឌ្ឍធនធានមនុស្ស និងការពង្រឹងសមត្ថភាព (ផលិតករ អ្នកសារព័ត៌មាន ពិធីករ) ដើម្បីជួយប្រព័ន្ធព័ត៌មានស្វែងយល់ពីវិទ្យាសាស្ត្រនៃការប្រែប្រួលអាកាសធាតុផលប៉ះពាល់និងដំណោះស្រាយ ។ ប្រព័ន្ធព័ត៌មានដើរតួសំខាន់ ក្នុងការផ្សព្វផ្សាយព័ត៌មានជូនសាធារណជន ស្តីពីការប្រែប្រួលអាកាសធាតុ ដែលជួយកាត់បន្ថយការយល់ច្រឡំដោយមនុស្សទូទៅស្តីពីការប្រែប្រួលអាកាសធាតុ។ ប្រព័ន្ធព័ត៌មានប្រកបដោយគុណភាពអាចជួយស្ថាបនាបាននូវសង្គមមួយទទួលបានព័ត៌មានត្រឹមត្រូវស្តីពីការប្រែប្រួលអាកាសធាតុដើម្បីធ្វើការសម្រេចចិត្តដាក់វិធានការបន្សាំ និងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ជាលក្ខណៈគ្រួសារ និងបុគ្គល។ |
| ប្រភេទសកម្មភាពឆ្លើយតបការប្រែប្រួលអាកាសធាតុ | កែសម្រួលសកម្មភាពដែលមានស្រាប់របស់ក្រសួង |
| លក្ខណៈពិសេសនៃសកម្មភាព | ការកាត់បន្ថយ និងការបន្សាំ |
| ការបរិយាយខ្លីអំពីសកម្មភាពលទ្ធផលនិងផលប្រយោជន៍រំពឹងទុក | • បណ្តុះបណ្តាលគ្រូបង្គោលសម្រាប់មន្ត្រីក្រសួងព័ត៌មាន (កញ្ចប់កម្មវិធីសរុប ៣កម្មវិធីក្នុងមួយកម្មវិធី ២ថ្ងៃ)<br>• មន្ត្រីទទួលបានការបណ្តុះបណ្តាលរួចហើយ ចុះទៅតាមមូលដ្ឋានបង្រៀនមន្ត្រីមន្ទីរព័ត៌មាន មនុស្សចាស់ ប្រធានភូមិ<br>• សិក្ខាសាលាបណ្តុះបណ្តាល ដល់អ្នកសារព័ត៌មាន ផលិតករ ពិធីករព័ត៌មាន ស្តីពីការប្រែប្រួលអាកាសធាតុ(៤កម្មវិធីក្នុងមួយកម្មវិធី ២ថ្ងៃ) ចុះអនុវត្តផ្ទាល់<br>• ផ្តល់ការបណ្តុះបណ្តាលសម្រាប់អង្គភាពព័ត៌មានធំៗកាសែត វិទ្យុ ទូរទស្សន៍ និងទស្សនាវដ្តី |

| | |
|---|---|
| | • ពង្រឹងសមត្ថភាពអ្នកផ្ដើយផ្ដងព័ត៌មាន ឯកជននិងសាធារណៈស្ដីពីវិទ្យាសាស្ត្រ និងបរិស្ថាន<br>លទ្ធផលនិងផលប្រយោជន៍រំពឹងទុក<br>• ក្រុមមនុស្សនិងទីភ្នាក់ងារព័ត៌មានគោលដៅដែលទទួលបានការបណ្ដុះបណ្ដាលនឹងយល់ពីការប្រែប្រួលអាកាសធាតុ ពួកគេនឹងមានសក្ដានុពលពាំនាំព័ត៌មានត្រឹមត្រូវនិងទាន់ពេលវេលាស្ដីពីការប្រែប្រួលអាកាសធាតុ ជូនមនុស្សទូទៅ និងអ្នកធ្វើគោលនយោបាយសាធារណៈ<br>• សាធារណជននឹងទទួលបានព័ត៌មានគុណភាពស្ដីពីការប្រែប្រួលអាកាសធាតុ |
| ប្រសិទ្ធភាពនៃការចំណាយលើសកម្មភាព | • សាធារណជនយល់ដឹងពីការប្រែប្រួលអាកាសធាតុ ដែលអាចកាត់បន្ថយ ហានិភ័យ<br>• សង្គមដែលទទួលបានព័ត៌មានច្បាស់លាស់ស្ដីពីការប្រែប្រួលអាកាសធាតុមានសមត្ថភាពបន្សាំខ្ពស់អាចកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ជាបុគ្គល និងជាគ្រួសារ |
| លក្ខខណ្ឌចម្បងដើម្បីអនុវត្តឲ្យបានជោគជ័យ | • ត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រី ដើម្បីអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពស្ដីពីការប្រែប្រួលអាកាសធាតុ លើវិស័យព័ត៌មាន។<br>• ការចូលរួមពីប្រព័ន្ធព័ត៌មានឯកជននិងអ្នកជំនាញខាងការប្រែប្រួលអាកាសធាតុ ក្នុងកម្មវិធីអភិវឌ្ឍសមត្ថភាពស្ដីពីការប្រែប្រួល អាកាសធាតុលើវិស័យព័ត៌មាន<br>• សហការជាមួយក្រសួងបរិស្ថាន និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីរៀបចំកម្មវិធីបណ្ដុះបណ្ដាល ស្ដីពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ<br>• ការចូលរួមរបស់បុគ្គលិក និងប្រព័ន្ធព័ត៌មានឯកជន |
| សូចនាករនៃសកម្មភាព | • យ៉ាងហោចណាស់គ្រូបង្គោល៣០នាក់របស់ក្រសួងព័ត៌មានទទួលការបណ្ដុះបណ្ដាលស្ដីពីការប្រែប្រួលអាកាសធាតុ<br>• យ៉ាងហោចណាស់ មន្ត្រី២នាក់មកពីមន្ទីរព័ត៌មានរាជធានី-ខេត្តនីមួយៗទទួលការបណ្ដុះបណ្ដាលស្ដីពីការប្រែប្រួលអាកាសធាតុ<br>• ចំនួនអ្នកសារព័ត៌មានឯកជន ដូចជា កាសែត វិទ្យុ ទូរទស្សន៍ ទស្សនាវដ្ដីទទួលបានការបណ្ដុះបណ្ដាលស្ដីពីការប្រែប្រួលអាកាសធាតុ |
| ទម្រង់ការអនុវត្ត | នាយកដ្ឋានទទួលបន្ទុក |

| | |
|---|---|
| | នាយកដ្ឋានបណ្តុះបណ្តាល និងអគ្គនាយកដ្ឋានជំនាញ<br>ស្ថាប័នរដ្ឋពាក់ព័ន្ធការអនុវត្ត<br>NCDM, MOWRAM, MAFF, MoE<br>ការចូលរួមពីឯកជន: iClick, Westline, ... |
| តម្លៃប៉ាន់ស្មានសរុប | **៣០០ ០០០** |
| ប្រភពដែលអាចផ្តល់មូលនិធិ | *UNDP/CCCA, ADB, WB, USAID, Government* |
| គ្រប់ខ័ណ្ឌពេលវេលា | ២០១៥-២០១៦ |

| | |
|---|---|
| ***សកម្មភាព ២*** | ផលិតកម្មវិធី យល់ដឹងពីការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ |
| គោលដៅជាយុទ្ធសាស្ត្រ CCCSP | គោលដៅជាយុទ្ធសាស្ត្រទី ៥ ៖ កែលម្អសមត្ថភាព ចំណេះដឹង និងការយល់ដឹង ស្តីពីការប្រែប្រួលអាកាសធាតុ |
| ហេតុផល | អាទិភាពរបស់ក្រសួងព័ត៌មាន ដែលចុះក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៤-២០១៨ ផ្តោតលើការផលិតកម្មវិធីដែលមានប្រធានបទអប់រំក្នុងសង្គម ច្បាប់ យេនឌ័រ កុមារ និងកម្មវិធីយល់ដឹងនានា សម្រាប់គ្រប់សហគមន៍ ។ រួមចំណែកលើកកម្ពស់ការយល់ដឹងស្តីពីការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ ។ សង្គមដែលទទួលព័ត៌មានច្បាស់លាស់ស្តីពីការប្រែប្រួលអាកាសធាតុ នឹងផ្លាស់ប្តូរឥរិយាបថ អត្តចរិតឆ្ពោះទៅរកសង្គមដែលស៊ាំនឹងអាកាសធាតុដែលប្រការនេះអាចបង្កើនសមត្ថភាពបន្សាំ និងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ |
| ប្រភេទនៃសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | កែសម្រួលសកម្មភាពដែលមានស្រាប់របស់ក្រសួង |
| លក្ខណៈពិសេសនៃសកម្មភាព | ការកាត់បន្ថយនិងការបន្សាំ |
| បរិយាយខ្លីៗអំពីសកម្មភាព ព្រមទាំង លទ្ធផល និងផលប្រយោជន៍រំពឹងទុក | • ទី១ ផលិតឯកសារស្តីពីការសិក្សាករណីជាក់ស្តែង បង្ហាញពីការអនុវត្តបានល្អស្តីពីការបន្សាំ នៅតាមសហគមន៍ និងទី២ បង្ហាញពីការប្រឹងប្រែង ក្នុងការកាត់បន្ថយដែលចូលរួមពីវិស័យឯកជន ។<br>• ផលិតវីដេអូខ្លី កម្មវិធីយល់ដឹងពីការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ នៅប្រទេសកម្ពុជា សម្រាប់ក្រុមគោលដៅផ្សេងគ្នា ។<br>• យុទ្ធនាការផ្សព្វផ្សាយ វីដេអូខ្លីបទយកការណ៍ តាមសហគមន៍ (ប្រគុំតន្ត្រី ចែកជាសវីដេអូ ។ល។) |

| | |
|---|---|
| | • ស្ដាបនាគេហទំព័រ និងបណ្ដាញសង្គម (ហ្វេសប៊ុក យូធូប) ដើម្បីចែករំលែកវីដេអូខ្លីនិងបទយកការណ៍ឲ្យប្រជាជនទទួលបានព័ត៌មានស្ដីពីការប្រប្រួលអាកាសធាតុ ។<br>• មហាជននឹងយល់ថែមទៀតអំពីការប្រែប្រួលអាកាសធាតុ ។ ប្រសិនបើកម្មវិធីស្ដីពីការប្រែប្រួលអាកាសធាតុផ្សាយតាម វិទ្យុនិងទូរទស្សន៍ជាតិ ប្រជាជន៨០%នឹងទទួលបានព័ត៌មាននិងចំណេះដឹងស្ដីពីការប្រែប្រួលអាកាសធាតុ ។ |
| ប្រសិទ្ធភាពនៃការចំណាយលើសកម្មភាព | • ដោយសារសកម្មភាពចូលរួម នាំឲ្យប្រជាជនផ្លាស់ប្ដូរឥរិយាបថ នឹងជួយបន្ថយកម្រិតហានិភ័យអាកាសធាតុនិងការប្រើងប្រែងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ។ ផលប៉ះពាល់មានកម្រិតទាប ដោយហេតុថា ៨៥% នៃប្រជាជនកម្ពុជារស់នៅក្នុងតំបន់ដែលអាចទទួលបានដំណឹងពីបណ្ដាញព័ត៌មាន ។ |
| លក្ខខណ្ឌចម្បងដើម្បីអនុវត្តឲ្យបានជោគជ័យ | • ផលិតករ ត្រូវការយល់ដឹងឲ្យបានត្រឹមត្រូវ អំពីការប្រែប្រួលអាកាសធាតុ ។ មុនពេលផលិតកម្មវិធីផលិតក រត្រូវទទួលការបណ្ដុះបណ្ដាលស្ដីពីការប្រែប្រួលអាកាសធាតុ ។<br>• មន្ត្រីក្រសួងព័ត៌មានចាំបាច់ត្រូវមានការបណ្ដុះបណ្ដាលមុនគេ ស្ដីពីការប្រែប្រួលអាកាសធាតុ ។<br>ការសហការជាមួយក្រសួងផ្សេងទៀត និងអ្នកពាក់ព័ន្ធ<br>• សំខាន់ត្រូវទទួលយកមតិយោបល់បច្ចេកទេសពីក្រសួងស្ថាប័នពាក់ព័ន្ធ (MoE, MAFF, MOWRAM, MRD, MME, MPWT, and NCDM) ដើម្បីធានាគុណភាពនៃកម្មវិធី។<br>សមត្ថភាពអប្បបរមា<br>• ក្រសួងព័ត៌មាន មានបទពិសោធន៍និងជំនាញផលិតកម្មវិធីអប់រំសម្រាប់ទូរទស្សន៍ វិទ្យុ និងកាសែត។ |
| សូចនាករជោគជ័យ | • ចំនួនកម្មវិធីដែលត្រូវផលិត (បទយកការណ៍ វីដេអូខ្លី រឿងខ្លី ។ល។)<br>• ចំនួនយុទ្ធនាការស្ដីពីការប្រែប្រួលអាកាសធាតុនៅតាមសហគមន៍ ។<br>• ការស្ដាបនាគេហទំព័រ ។<br>• កម្មវិធីហ្វេសប៊ុក យូធូប ចែករំលែកព័ត៌មានលើបណ្ដាញសង្គម ។ |
| ទម្រង់ការ អនុវត្ត | នាយកដ្ឋានទទួលបន្ទុក |

| | |
|---|---|
| | • អគ្គនាយកដ្ឋានទូរទស្សន៍ជាតិ អគ្គនាយកដ្ឋានវិទ្យុជាតិ អគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា ..........<br>ស្ថាប័នរដ្ឋ អ្នកពាក់ព័ន្ធនិងវិស័យឯកជន<br>ស៊ីធីអិន ហង្សមាស បាយ័ន ...... |
| តម្លៃប៉ាន់ស្មានសរុប | ១ ២០០ ០០០ |
| ប្រភពដែលផ្តល់មូលនិធិ | *UNDP/CCCA, ADB, WB, USAID, Government* |
| ក្របខ័ណ្ឌពេលវេលា | ២០១៥-២០១៨ |

| | |
|---|---|
| **សកម្មភាព ៣** | ស្នើឲ្យប្រព័ន្ធព័ត៌មានឯកជនចូលរួមផ្សាយប្រធានបទស្តីពីការប្រែប្រួលអាកាសធាតុ ផលប៉ះពាល់ និងដំណោះស្រាយ |
| គោលដៅជាយុទ្ធសាស្ត្រ CCCSP | គោលដៅជាយុទ្ធសាស្ត្រទី ៥ ៖ កែលម្អសមត្ថភាព ចំណេះដឹង និងការយល់ដឹង ស្តីពីការប្រែប្រួលអាកាសធាតុ |
| ហេតុផល | • ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិថ្លៃងថា ក្រសួងព័ត៌មានគ្រោងនឹងសហការ និងលើកទឹកចិត្ត ផ្នែកឯកជនជួយផ្សព្វផ្សាយ ឲ្យបានទូលំទូលាយ លើកកម្ពស់កម្មវិធីអប់រំ និងកែលម្អគុណភាពព័ត៌មាន ។<br>• សហការជាមួយប្រព័ន្ធផ្សព្វផ្សាយឯកជន ពង្រីកវិសាលភាពនៃការផ្សាយដល់សាធារណជន ។ ដោយសារប្រព័ន្ធព័ត៌មាន ជាមធ្យោបាយមានប្រសិទ្ធភាពបំផុត ក្នុងការចែករំលែកព័ត៌មានកិច្ចសហប្រតិបត្តិការជាមួយប្រព័ន្ធផ្សព្វផ្សាយឯកជន និងធានាបានថា សាធារណជនទទួលបានព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ គួរឲ្យទុកចិត្តបាន និងទាន់ពេលវេលា ។ |
| ប្រភេទនៃសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | កែសម្រួលសកម្មភាពដែលមានស្រាប់របស់ក្រសួង |
| លក្ខណៈពិសេសនៃសកម្មភាព | ការកាត់បន្ថយ និងការបន្សាំ |
| បរិយាយខ្លីអំពីសកម្មភាពព្រមទាំងលទ្ធផល និងផលប្រយោជន៍ រំពឹងទុក | • កសាងឯកសារណែនាំកម្មវិធីផ្សាយរបស់ប្រព័ន្ធផ្សព្វផ្សាយឯកជនស្តីពីការប្រែប្រួលអាកាសធាតុ<br>• គាំទ្រផ្នែកបច្ចេកទេសដល់ប្រព័ន្ធផ្សព្វផ្សាយឯកជនស្តីពីការប្រែប្រួលអាកាសធាតុ<br>• ភាពជាដៃគូជាមួយប្រព័ន្ធផ្សព្វផ្សាយឯកជនដើម្បីផ្សព្វផ្សាយព័ត៌មាន |

| | |
|---|---|
| | ស្តីពី ការប្រែប្រួលអាកាសធាតុ<br>• ភាពជាដៃគូជាមួយប្រព័ន្ធផ្សព្វផ្សាយឯកជនដើម្បីផ្សព្វផ្សាយ វីដេអូខ្លី និង បទយកការណ៍ ស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា<br>• ផ្តល់ការគាំទ្រជាសម្ភារ និងថវិកាដល់ប្រព័ន្ធព័ត៌មានឯកជន ផ្សាយព័ត៌មាន ស្តីពីការប្រែប្រួលអាកាសធាតុ<br>• មហាជនយល់ដឹងអំពីបញ្ហានៃការប្រែប្រួលអាកាសធាតុ |
| ប្រសិទ្ធភាពនៃការចំណាយលើសកម្មភាព | • សហការជាមួយប្រព័ន្ធផ្សព្វផ្សាយឯកជន ធ្វើឲ្យប្រជាជន១០០% ទទួលបាន ព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ |
| លក្ខខណ្ឌចម្បងដើម្បីអនុវត្តឲ្យបានជោគជ័យ | • ធនធ: និងកិច្ចសហការពីប្រព័ន្ធផ្សព្វផ្សាយឯកជន កិច្ចសហការពីក្រសួងពាក់ព័ន្ធ: MOWRAM, MAFF, NCDM, etc. ដើម្បីទទួលបានព័ត៌មានស្តីពី ការប្រែប្រួលអាកាសធាតុ<br>• ក្រសួងព័ត៌មានដើរតួនាទី ជាអ្នកដឹកនាំ<br>• ក្រសួងព័ត៌មាន មានបទពិសោធនិងជំនាញ ផលិតកម្មវិធីអប់រំ សម្រាប់ទូរទស្សន៍ វិទ្យុ និងកាសែត ។ |
| សូចនាករជោគជ័យ | • និតិវិធីដើម្បីសហការជាមួយប្រព័ន្ធព័ត៌មានឯកជន.<br>• ចំនួន...ប្រព័ន្ធព័ត៌មានឯកជន ចូលរួមផ្សាយព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ<br>• ចំនួន...ម៉ោងផ្សាយព័ត៌មាន ស្តីពីការប្រែប្រួលអាកាសធាតុតាមទូរទស្សន៍ វិទ្យុ |
| ទម្រង់ការអនុវត្ត | នាយកដ្ឋានទទួលបន្ទុក<br>• អគ្គនាយកដ្ឋានទូរទស្សន៍ជាតិ អគ្គនាយកដ្ឋានវិទ្យុជាតិ អគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា ..........<br>ស្ថាប័នរដ្ឋ អ្នកពាក់ព័ន្ធ និងវិស័យឯកជន<br>• MoE, MOWRAM, MAFF, NCDM, ណែនាំបច្ចេកទេសពីសារៈសំខាន់ដើម្បីគុណភាពព័ត៌មាន |
| តម្លៃប៉ាន់ស្មានសរុប | ៥០០ ០០០ |
| ប្រភពដែលអាចផ្តល់មូលនិធិ | UNDP/CCCA, ADB, WB, USAID, Government |
| ក្របខ័ណ្ឌពេលវេលា | ២០១៥-២០១៨ |

| | |
|---|---|
| សកម្មភាព ៤ | ពង្រឹង និងពង្រីកមធ្យោបាយផ្សព្វផ្សាយ ការយល់ដឹងស្តីពីការប្រែប្រួលអាកាសធាតុ |
| គោលដៅជាយុទ្ធសាស្ត្រ CCCSP | គោលដៅជាយុទ្ធសាស្ត្រទី ៥ ៖ កែលម្អសមត្ថភាព ចំណេះដឹង និងការយល់ដឹងស្តីពីការប្រែប្រួលអាកាសធាតុ |
| ហេតុផល | • យុទ្ធសាស្ត្រចតុកោណ គម្រោងវិនិយោគសាធារណៈរបស់ក្រសួង ស្តីពីការពង្រីកស្ថានីយវិទ្យុនិងទូរទស្សន៍<br>• ជួយសាធារណជន ឲ្យទទួលបានព័ត៌មានអាកាសធាតុទាន់ពេល និងងាយស្រួល ។ សកម្មភាពនេះរួមចំណែកលើកកម្ពស់ការយល់ដឹង ស្តីពីការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ ។ សង្គមទទួលបានព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុបានត្រឹមត្រូវ នាំឲ្យប្រជាជនប្តូរឥរិយាបថនិងអត្តចរិតក្នុងសង្គមដែលយល់ដឹងពីការប្រែប្រួលអាកាសធាតុ ។ គេអាចបង្កើនសមត្ថភាពបន្សាំ និងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ។ ការពង្រីកតំបន់គ្របដណ្តប់ការផ្សាយ ធ្វើឲ្យសាធារណជនកាន់តែច្រើនទទួលបាន ព័ត៌មាន ស្តីពីការប្រែប្រួលអាកាសធាតុ ទាន់ពេលវេលា។ |
| ប្រភេទនៃសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | កែសម្រួលសកម្មភាពដែលមានស្រាប់របស់ក្រសួង |
| លក្ខណៈពិសេសនៃសកម្មភាព | ការកាត់បន្ថយ និងការបន្សាំ |
| បរិយាយខ្លីអំពីសកម្មភាព ព្រមទាំងលទ្ធផល និងផលប្រយោជន៍ រំពឹងទុក | • ឧបករណ៍សម្ភារផ្សាយរបស់ទូរទស្សន៍ និងវិទ្យុ បច្ចុប្បន្នចាស់ហួសសម័យ ។ នៅតាមខេត្តម៉ាស៊ីនភាគច្រើនមិនអាចដំណើរការពេញសមត្ថភាព<br>• នៅថ្នាក់ជាតិធ្វើការជាមួយស្ថានីយទូរទស្សន៍និងវិទ្យុខេត្ត ដើម្បីផ្សាយនិងផ្សាយឡើងវិញព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ ។<br>• ផ្តល់ការគាំទ្រខាងបច្ចេកទេស និងហិរញ្ញវត្ថុ<br>• បណ្តុះបណ្តាលបុគ្គលិកមន្ទីរព័ត៌មាន<br>• បច្ចុប្បន្ន ការផ្សាយរបស់ទូរទស្សន៍ជាតិ គ្របដណ្តប់បាន ៨៥%នៃប្រជាពលរដ្ឋ ។ ដូច្នេះ ការពង្រីក១៥%ទៀត គឺជួយដល់ពលរដ្ឋរស់នៅក្នុងតំបន់ដែលគ្មានអត្ថប្រយោជន៍សេដ្ឋកិច្ច។ |
| ប្រសិទ្ធភាពនៃការចំណាយលើសកម្មភាព | • ការចំណាយលើការតម្លើងឬការពង្រីកស្ថានីយតាមខេត្ត ដែលត្រូវការថវិកាដំបូងចំនួនច្រើន ពិសេសការចំណាយលើ ឧបករណ៍ និងអគារសម្រាប់ |

| | |
|---|---|
| | ម៉ាស៊ីនផ្សាយ។ |
| លក្ខខណ្ឌចម្បងដើម្បីអនុវត្តឲ្យបានជោគជ័យ | • វាយតម្លៃខាងបច្ចេកទេសលើស្ថានីយទូរទស្សន៍តាមខេត្ត ដើម្បីដឹងច្បាស់ពីតម្រូវការជាក់ស្តែង។<br>• ស្រាវជ្រាវទីផ្សារ ដើម្បីកែលម្អតម្រូវការរបស់វិទ្យុនិងទូរទស្សន៍ ។ ដូច្នេះ គេត្រូវការធ្វើយុទ្ធនាការទីផ្សារសង្គមនៅតាមតំបន់ឆ្ងាយ ។<br>• សហការជាមួយអាជ្ញាធរមូលដ្ឋាន ស្រាវជ្រាវទីផ្សារសង្គម ដើម្បីកំណត់តម្រូវការរបស់វិទ្យុនិងទូរទស្សន៍នៅជនបទ ។<br>• ចំណេះដឹងបច្ចេកទេសរបស់បុគ្គលិកតាមមន្ទីរព័ត៌មាន ស្តីពីការប្រើប្រាស់ឧបករណ៍ផ្សាយថ្មី តាមរយៈការបណ្តុះបណ្តាល ។ |
| សូចនាករជោគជ័យ | • ចំនួន...ស្ថានីយទូរទស្សន៍ និងវិទ្យុចូលរួមផ្សាយបន្ត នូវព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ<br>• ចំនួន...ម៉ោងក្នុង១ខែផ្សាយបន្តនូវព័ត៌មាន ស្តីពីការប្រែប្រួលអាកាសធាតុ |
| ទម្រង់ការអនុវត្ត | **នាយកដ្ឋានទទួលបន្ទុក**<br>• អគ្គនាយកដ្ឋានទូរទស្សន៍ជាតិ<br>• អគ្គនាយកដ្ឋានវិទ្យុជាតិ<br>• មន្ទីរព័ត៌មាន |
| តម្លៃប៉ាន់ស្មានសរុប | ២០០ ០០០ |
| ប្រភពដែលផ្តល់មូលនិធិ | • រាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលជប៉ុន |
| ក្របខ័ណ្ឌពេលវេលា | • ២០១៥-២០១៨ |

| | |
|---|---|
| **សកម្មភាព ៥** | ពង្រីកតំបន់គ្របដណ្តប់ការផ្សាយរបស់វិទ្យុនិងទូរទស្សន៍ជាតិ ដើម្បីជួយសម្រួលឲ្យសាធារណជនទទួលបានការផ្សាយព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ។ |
| គោលដៅជាយុទ្ធសាស្ត្រ CCCSP | គោលដៅជាយុទ្ធសាស្ត្រទី ៥ ៖ កែលម្អសមត្ថភាព ចំណេះដឹង និងការយល់ដឹងស្តីពីការប្រែប្រួលអាកាសធាតុ |
| ហេតុផល | • ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (២០១៤ ២០១៨) ចែងថា ក្រសួងព័ត៌មាននឹងបន្តកសាងស្ថានីយវិទ្យុនិងទូរទស្សន៍នៅថ្នាក់ក្រោមជាតិដោយផ្តល់អាទិភាពទៅតំបន់ពាយព្យ និងឦសាន ។ ស្ថានីយទាំងនោះដើរតួនាទីជាស្ពានចម្លងគោលនយោបាយនានារបស់រាជរដ្ឋាភិបាលជូនប្រជាពលរដ្ឋ ។<br>• រួមចំណែកលើកកម្ពស់ការយល់ដឹងស្តីពីការប្រែប្រួលអាកាសធាតុនិងផល |

| | |
|---|---|
| | ប៉ះពាល់ ។ សង្គមទទួលបានព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ បាន ត្រឹមត្រូវ នាំឲ្យប្រជាជនប្តូរឥរិយាបថនិងអត្តចរិតក្នុងសង្គមដែលយល់ដឹងពី ការប្រែប្រួលអាកាសធាតុ ។ គេអាចបង្កើនសមត្ថភាពបន្សាំ និងកាត់បន្ថយ ការបំភាយឧស្ម័នផ្ទះកញ្ចក់ ។ ការពង្រីកតំបន់គ្របដណ្តប់ការផ្សាយធ្វើឲ្យ សាធារជនកាន់តែច្រើនទទួលបានព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ ទាន់ពេលវេលា។ |
| ប្រភេទនៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | កែសម្រួលសកម្មភាពដែលមានស្រាប់របស់ក្រសួង |
| លក្ខណៈពិសេសនៃសកម្មភាព | ការកាត់បន្ថយ និងការបន្សាំ |
| បរិយាយខ្លីអំពីសកម្មភាពព្រមទាំងលទ្ធផល និងផលប្រយោជន៍ រំពឹងទុក | • តំបន់ខ្លះមិនអាចទទួលបានការផ្សាយវិទ្យុ និងទូរទស្សន៍ហើយនៅទីនោះ ជារឿយៗ ទទួលរងខ្យល់ព្យុះ ទឹកជំនន់ និងរាំងស្ងួត។ ឧទាហរណ៍ ស្រុកមួយចំនួននៅស្វាយរៀងមិនអាចទទួលបានការផ្សាយ វិទ្យុ និងទូរទស្សន៍ និងប្រឈមគ្រោះរាំងស្ងួត និងទឹកប្រៃជ្រាបចូល ។ អ្នកស្រុកមានទូរទស្សន៍ វិទ្យុ មានម៉ាស៊ីនភ្លើងឬអាគុយ ប៉ុន្តែមិនអាចទទួលបានការផ្សាយពី វិទ្យុ និងទូរទស្សន៍ជាតិ។<br>• ការពង្រីកតំបន់គ្របដណ្តប់ការផ្សាយ វិទ្យុ និងទូរទស្សន៍ធ្វើឲ្យសាធារណជនទទួលបានព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ ។<br>• បង្កើតស្ថានីយទូរទស្សន៍និងវិទ្យុជាតិផ្សាយបន្ត ដើម្បីផ្សាយឡើងវិញ នូវព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ ។<br>• តំឡើងឧបករណ៍ទូរទស្សន៍ផ្កាយរណប(DTV) នៅខេត្តស្វាយរៀង ឧត្តរមានជ័យ ប៉ៃលិន ព្រះវិហារ បន្ទាយមានជ័យ មណ្ឌលគិរី ស្ទឹងត្រែង និងរតនគិរី<br>១០០ គ្រឿង មណ្ឌលគិរី (កោះញែក)<br>៥០០ គ្រឿង ឧត្តរមានជ័យ<br>៥០០ គ្រឿង ព្រះវិហារ<br>៥០០ គ្រឿង ស្វាយរៀង (ស្វាយទាប, ស្វាយតឿ)<br>៥០០ គ្រឿង បន្ទាយមានជ័យ<br>១០០ គ្រឿង រតនគិរី<br>១០០ គ្រឿង ស្ទឹងត្រែង ( សៀមប៉ាង ថាឡាបរីវ៉ាត់) |

| | |
|---|---|
| | • តម្លៃឧបករណ៍ទូរទស្សន៍ផ្កាយរណប ( DTV)$១០០ x ២៣០០ គ្រឿង = ២៣០០០០ ដុល្លារ ហើយមនុស្ស២៣០០០គ្រួសារទទួលបានប្រយោជន៍នេះ ។<br>• ដើម្បីធ្វើឲ្យបណ្តាញព័ត៌មានជាតិគ្របដណ្តប់បាន១០០%ក្រសួងត្រូវពង្រីកតំបន់គ្របដណ្តប់២០%ទៀត ។ ២០% នេះ<br>មានសារសំខាន់ណាស់សម្រាប់តំបន់ ដែលនៅឆ្ងាយនិងងាយទទួលរងគ្រោះ ។ |
| ប្រសិទ្ធភាពនៃការចំណាយលើសកម្មភាព | • ប្រជាពលរដ្ឋ ២៣០០០គ្រួសារទទួលបានប្រយោជន៍នេះដោយផ្ទាល់ ។ |
| លក្ខខណ្ឌចម្បងដើម្បីអនុវត្តឲ្យបានជោគជ័យ | • ស្រាវជ្រាវពីចំនួនទូរទស្សន៍ដែលប្រជាពលរដ្ឋមានអោយបានជាក់លាក់ ។ |
| សូចនាករជោគជ័យ | • ចំនួន...ស្ថានីយ ដែលត្រូវបង្កើតថ្មី<br>• ចំនួន...គ្រួសារទទួលឧបករណ៍DTV |
| ទម្រង់ការអនុវត្ត | នាយកដ្ឋានទទួលខុសត្រូវ<br>• ក្រុមការងាររៀបចំផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់ក្រសួងព័ត៌មាន |
| តម្លៃប៉ាន់ស្មាន | ៣៣០ ០០០ |
| ប្រភពដែលអាចផ្តល់មូលនិធិ | • ភ្នាក់ងាររបស់សហប្រជាជាតិផ្នែកឯកជនដែលផ្តល់DTV សហការជាមួយទូរទស្សន៍ជាតិ ឬ អង្គការសង្គមស៊ីវិល |
| ក្របខ័ណ្ឌពេលវេលា | ២០១៥- ២០១៨ |